សៀវភៅ

# អធិប្បាយ

# ប្រជុំកខធម៌ពិស្តារ

រៀបរៀង

បណ្ឌិត **ឈឹម ទូច**

**ព.ស.២៤៩៥ គ.ស.១៩៥៣**

# អាទ្យបទ

~~~~~~~~~~

បុព្វហេតុដែលនាំឱ្យកើតសៀវភៅ ‹‹អធិប្បាយប្រជុំកងធម៌ពិស្ដារ›› នេះឡើង ដោយពួកសិស្សានុសិស្សទាំងឡាយ ដែលនៅរៀនក្នុងសំណាក់អនុគណបាននិយាយនឹងយើងខ្ញុំជាច្រើនរូប ស្មើរតែគ្រប់អនុគណដែលខ្ញុំបានទៅជួបជាច្រើនវត្តតែងនិយាយថា សៀវ-ភៅដែលបានបោះពុម្ពមុននោះ សេចក្ដីអធិប្បាយខ្លីៗពេក ចង់បានរឿងរ៉ាវជារបៀបទេសនា ហេតុនេះ បានជាខ្ញុំប្រឹងប្រែងតែងឡើងជារបៀបទេសនា ដើម្បីតម្រូវចិត្តសិស្សានុសិស្សទាំងនុ៎ះផង ដើម្បីជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាផង, ក្នុងការរៀបរៀងសៀវភៅនេះ ខ្ញុំបានពឹងសាមណេរ **ឈាត់-ប៉ុណ្យ** មហាបរិយត្តិបឋម-វិជ្ជា ឱ្យជាអ្នកសរសេរនិងតែងរឿងរ៉ាវខ្លះបន្ថែមផង និង
~~~~~~~~~~

មហាឧត្តមវិជ្ជា **ឃុន-គិមប៉ូរ** ជាអ្នកជួយអធិប្បាយធម៌ និងធ្វើរឿងរ៉ាវហើយនិងផ្ទៀងផ្ទាត់ពាក្យខុសត្រូវ និងកែប្រយោគខ្មែរខ្លះ ក្នុងសៀវភៅនេះផង; សៀវភៅនេះ ខ្ញុំបែកជា ២ ភាគ គឺពួកធម៌ ២ ដល់ពួកធម៌ ៤ ចាត់ជាភាគទី ១, ពីពួកធម៌ ៥ ដល់ពួកធម៌ ១៦ ចាត់ជាភាគទី ២ លុះដល់រៀបរៀងភាគទី ១ ចប់ហើយ ខ្ញុំក៏យកទៅចាត់ការបោះពុម្ពផ្សាយ ជាសាធារណប្រយោជន៍ទូទៅក្នុងសាសនមណ្ឌលទាំងមូល ។

ដោយអំណាចពលានុភាព នៃការរៀបរៀងសៀវភៅនេះ សូមឱ្យសាសនានៃព្រះភគវន្តមុនីនាថប្រតិស្ឋានទៅអស់កាលជាយូរអង្វែងតទៅ ។

មួយទៀត សូមឱ្យសិក្ខាកាមកុលបុត្រទាំងឡាយបានសម្រេចប្រយោជន៍តាមគោលបំណង កុំបីឃ្លៀង-ឃ្លាតក្លាយទៅជាអ្វីឡើយ !!

មួយវិញទៀត សុំអភ័យទោសអំពីសំណាក់នៃបណ្ឌិតទាំងឡាយ បើឃើញខុសខាតលើសលស់ផ្តាំផ្តង ឬមិនសមរម្យពាក្យពេចន៍ណាមួយ សូមកែតម្រង់ឱ្យទានផង, បើគ្រាន់តែសន្និះសង្ស័យទេ សូមពិគ្រោះនឹងខ្ញុំជាអ្នករៀបរៀងសិន ក្រែងមានសេចក្តីយល់ខុសគ្នា ការរៀបរៀងសៀវភៅអធិប្បាយប្រជុំកថធម៌ពិស្តារនេះ ទុកដើម្បីជាប្រយោជន៍ដល់ព្រះពុទ្ធសាសនា ។

ភ្នំពេញ, ថ្ងៃ ៤ ៗ ៣ ៥ ឆ្នាំរោង ចត្វាស័ក ព.ស.២៤៩៥
ត្រូវនឹងថ្ងៃ ១ ខែមេសា គ.ស.១៩៥៣
បណ្ឌិត ឈឹម-ទូច

មាតិកាធម៌

ឈ្មោះធម៌ ទំព័រ

## ទុកៈ ពួក ២

ធម៌មានឧបការៈច្រើន ២ យ៉ាង.....................

លោកបាលធម៌ ២ យ៉ាង...............................

ធម៌ធ្វើឱ្យល្អ ២ យ៉ាង .................................

បុគ្គលរកបានដោយកម្រ ២ យ៉ាង ...............

## តិកៈ ពួក ៣

រតនៈ ៣ យ៉ាង .........................................

គុណរបស់ព្រះរតនៈ ៣ យ៉ាង ......................

អាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង ....

ឱវាទរបស់ព្រះពុទ្ធ ៣ យ៉ាង .........................

ទុច្ចរិត ៣ យ៉ាង .........................................

សុចរិត ៣ យ៉ាង .........................................

អកុសលមូល ៣ យ៉ាង ................................

កុសលមូល ៣ យ៉ាង ...................................

សប្បុរិសបញ្ញត្តិ ៣ យ៉ាង .............................

អាបណ្ណកប្បដិបទា ៣ យ៉ាង .........................

បុញ្ញកិរិយាវត្ថុ ៣ យ៉ាង ...............................

សាមញ្ញលក្ខណៈ ៣ យ៉ាង ..........................

# អធិប្បាយប្រជុំកងធម៌ពិស្ដារ

~~~~~~~~~~~~~~~~~~~~~~~~

នមត្ថុ រតនត្តយស្ស

*សូមនមស្ការចំពោះព្រះសុគត (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ) ដោយសេចក្ដីគោរព ។*

## ទុកៈ ពួក ២

## ធម៌មានឧបការៈច្រើន ២ យ៉ាង (1)

១-សតិ *សេចក្ដីរលឹកបាន;*

២-សម្បជញ្ញៈ *សេចក្ដីដឹងខ្លួន ។*

### អធិប្បាយ

សតិ *មានលក្ខណៈ រក្សាបុគ្គលមិនឱ្យប្រមាទភ្លាំងភ្លាត់ភ្លេចខ្លួន ។*

សម្បជញ្ញៈ *មានលក្ខណៈឱ្យដឹងខ្លួនក្នុងវេលាធ្វើ, វេលានិយាយ, វេលាគិតនូវកិច្ចានុកិច្ចដែលត្រូវធ្វើ, ត្រូវនិយាយ,*
~~~~~~~~~~~~~~~~~~~~~~~~

ត្រូវគិតនោះៗ មិនឱ្យខូចខាត ដូចជាមាតាបិតាចាំហាមបុត្រ-ធីតាមិនឱ្យធ្វើអំពើអាក្រក់ផ្សេងៗ ឱ្យតាំងនៅក្នុងធម៌ដ៏ល្អយ៉ាងណា, ចំណែកសម្បជញ្ញៈក៏យ៉ាងនោះដែរ ។

បានជាលោកចាត់ធម៌ទាំងពីរនេះ ថាមានឧបការៈច្រើននោះ ព្រោះបណ្ដាកុសលទាំងអស់ដែលស្ថិតនៅបាន ព្រោះអាស្រ័យសតិ និងសម្បជញ្ញៈ ទាំងពីរនេះជាមូលដ្ឋាន, បើប្រាសចាកធម៌ទាំងពីរនេះហើយ កុសលធម៌ទាំងអស់មិនអាចស្ថិតនៅបានឡើយ, សតិនេះជាតួអប្បមាទធម៌ គ្រាន់តែជាវេវចនៈផ្លាស់ប្ដូរពាក្យគ្នាហៅប៉ុណ្ណោះ, បានជាព្រះអង្គទៀបនឹងបរិនិព្វានទ្រង់បន្ទឺឱវាទវាចាជាទីបំផុតថា អប្បមាទេន សម្បាទេថ អ្នកទាំងឡាយចូរញ៉ាំងអប្បមាទធម៌ឱ្យសម្រេច គឺថាកុំធ្វេសប្រហែសឡើយ; ព្រះអង្គមានពុទ្ធដីកាតែប៉ុណ្ណោះ ហាក់ដូចជាចប់ធម៌ទាំងប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ គឺព្រះអង្គទ្រង់ប្រមើលមើលទៅឃើញតែសតិនេះហើយ ដែលជា

ធម៌មានឧបការៈច្រើនជាងកុសលធម៌ទាំងអស់, បានជាចាត់សតិនិងសម្បជញ្ញៈនេះថាជាធម៌មានឧបការៈច្រើន ។

ម្យ៉ាងទៀត ដូចជាការងារក្នុងបច្ចុប្បន្ននេះ បើបុគ្គលណាប្រាសចាកសតិនិងសម្បជញ្ញៈទាំងពីរនេះហើយ, ការងារនោះមុខជាភ្លាំងភ្លាត់ខាតមិនបានសម្រេច ដូចជាអ្នកបើលកប៉ាល់ជាដើម មនុស្សអ្នកជិះទាំងប៉ុន្មានស្ងាប់រស់នៅលើអ្នកបើកទាំងអស់, សតិទុកដូចជាអ្នកបើក, កុសលធម៌ទាំងអស់ទុកដូចជាអ្នកជិះដូច្នោះ ។

ម្យ៉ាងវិញទៀត ដូចជាមនុស្សពិការអវយវៈដៃ ឬជើងភ្នែក ត្រចៀក ច្រមុះ ជាដើម បើខូចខ្លះនោះខ្លះគង់បានប្រយោជន៍តិចច្រើនខ្លះមិនខាន, បើអវយវៈទាំងអស់នៅគ្រប់គ្រាន់ តែបើខូចសតិឆ្គួតហើយ មនុស្សនោះទៅជាឥតប្រយោជន៍គ្មានបានការអ្វីបន្តិចបន្តួចសោះ បានជាថាសតិនេះមានឧបការៈច្រើន ។ សតិនិងសម្បជញ្ញៈជាធម្មជាតិប្រាសចាកគ្នាមិនបាន, ប្រៀបដូចជាអាខ្វាក់អាខ្វិនតែងពឹង

អាស្រ័យគ្នាទៅវិញទៅមក នឹងលះបង់ចោលគ្នាមិនបាន ដូច្នោះ ។

សតិនេះ មានប្រយោជន៍ក្នុងបច្ចុប្បន្នក៏មាន បរលោកក៏មាន សមដូចពុទ្ធភាសិតសំដែងថា:

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។**

(ប្រែថា) យសគឺគ្រឿងឥស្សរិយយសនិងសេចក្តីរាប់អានរមែងចំរើនចំពោះបុគ្គលអ្នកមានព្យាយាម មានស្មារតី មានការងារដ៏ស្អាត អ្នកពិចារណាហើយទើបធ្វើ (នូវការងារ) អ្នកសង្រួម អ្នករស់នៅប្រកបដោយធម៌ និង បុគ្គលអ្នកមិនប្រមាទ ។

បុគ្គលដែលមានស្មារតីនោះ បើទុកជាដេកលក់ក៏ដោយក៏គង់មានសតិភ្ញាក់រឭកចំពោះការងារនោះៗ ដែរ ដូចមានរឿងដំណាលថា:

**អតីតេ ពារណសី នគរេ ពារាណសី ឯកោ មាណវោ តក្កសិលំ គន្ត្វា ។បេ។ សោ ធតា ចូឡបន្ថកោ អហោសិ, រាជា អានន្ទោ, ទិសាបាមោក្ខាចរិយោ អហមេវ ។**

*កាលដែលកន្លងទៅហើយ មានមាណពម្នាក់ នៅក្នុងក្រុងពារាណសី បានទៅរៀនសិល្បសាស្រ្តឯក្រុងតក្កសិលា ជាធម្មន្តេវាសិករបស់អាចារ្យទិសាបាមោក្ខ, ក្នុងពួកកូនសិស្ស ទាំង ៥០០ មានតែមាណពនេះឯងជាអ្នកធ្វើគុណូបការៈដល់អាចារ្យជាងគេ គឺតែងធ្វើការសព្វសារពើ មានគង់ប្រាប់ជាដើម, តែមិនអាចរៀនមន្តអ្វីចេះបានបន្តិចបន្តួចសោះ ព្រោះអាប់ប្រាជ្ញា ។ អាចារ្យគិតថា មាណពនេះមានឧបការៈដល់អញច្រើន, គួរតែអញបង្ហាត់ឱ្យវារៀនទៅចុះ ។ ទុកណាជាអាចារ្យបង្ហាត់ដូចម្តេច ក៏មាណពនោះនៅតែរៀនមិនចេះសោះ ទើបលាអាចារ្យ ត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញ ។ អាចារ្យគិតថា មាណពនេះមានឧបការៈច្រើនដល់អញ, បើដូច្នេះគួរតែអញធ្វើឧបការៈតបវិញ, ទើបនាំទៅព្រៃចងមន្តថា: «ឃដេសិ ឃដេសិ កឹ ការណា ឃដេសិ អហំបិ តំ*

**ជាធាមិ ជាធាមិ**›› ដូច្នេះ ឱ្យមាណពនោះ ទន្ទេញប្រាស បណ្ដាយជាច្រើនរយដងដរាបដល់ចាំស្ទាត់បាន, ទើបឱ្យ ស្បៀងអាហារលៀងជីពជន្មតាមផ្លូវដល់មាណពនោះ ហើយ ប្រាប់ថា ឯងអាស្រ័យនឹងមន្តប៉ុណ្ណោះ ក៏ល្មមចិញ្ចឹមជីវិតបាន ហើយ ត្រូវតែឧស្សាហ៍សូធ្យកុំឱ្យភ្លេច, លុះផ្ដែផ្ដាំស្រេចហើយ ក៏បញ្ជូនមាណពនោះឱ្យទៅនគរពារាណសីវិញ ។

គ្រានោះ, ព្រះបាទពារាណសី ទ្រង់ព្រះចិន្តាថា ‹‹អញ មានទោសអ្វីក្នុងកាយកម្មជាដើមខ្លះដែរឬ? ទ្រង់មិនឃើញ អំពើអ្វីមួយដែលមិនសមគួរនោះសោះ, ›› ទើបទ្រង់ឈ្វេង យល់ក្នុងព្រះទ័យថា ‹‹ធម្មតាទោសរបស់ខ្លួន រមែងមិន ប្រាកដដល់ខ្លួនឯង, តែងតែប្រាកដដល់អ្នកដទៃ, បើដូច្នេះ មានតែអញឃ្លាំស្ដាប់អ្នកនគរទើបដឹងបាន››; ហើយក៏ទ្រង់ ក្លែងភេទមិនឱ្យគេស្គាល់បាន, ទ្រង់យាងចេញទៅក្នុងវេលា រាត្រី ទ្រង់ស្ដេចចរយាត្រាសសៀរតាមក្បែរផ្ទះអ្នកស្រុកទាំង នោះ ។ ខណៈនោះ មានពួកចោរចូលមកលបទម្លាយឧម្មង្គ

ក្នុងចន្លោះផ្ទះទាំងសងខាង ដើម្បីនឹងចូលលួចផ្ទះទាំងពីរតាមឧម្មង្គតែមួយ ។ ព្រះរាជាទ្រង់ទស្សនាការហើយ ក៏ទ្រង់ព្រះស្ថិតសម្ងំស្ងៀមនៅក្នុងស្រមោលផ្ទះ ។ កាលដែលចោរកំពុងទំលាយឧម្មង្គចូលទៅលួចភោគទ្រព្យ, ចួនជាមាណពនោះមមើស្វាធ្យាយមន្ត ។ ពួកចោរបានឮដូច្នោះហើយក៏គិតគ្នាថា «យីអើ!, គេដឹងហើយវើយ !» ក៏ទម្លាក់សំពត់អាវចោល ភ័យរត់តែរៀងខ្លួនទៅ ។ ព្រះរាជាទ្រង់ទស្សនាការឃើញចោររត់ទៅដូច្នោះ, ក៏ទ្រង់សវនាការសំឡេងបុរសនោះស្វាធ្យាយមន្ត, និងឃ្នាំស្ដាប់អ្នកនគររួចហើយ ទ្រង់ស្ដេចយាងចូលទៅក្នុងព្រះរាជនិវេសន៍វិញ; លុះព្រឹកឡើង ទ្រង់មានព្រះរាជឱង្ការហៅអាមាត្យម្នាក់មក, ទ្រង់ត្រាស់ប្រើថា «នែប្រស្ដែង, អ្នកឯងចូរទៅ, ហ៎្ន: យប់មិញពួកចោរទំលាយឧម្មង្គក្រោមផ្ទះក្បែរផ្លូវឯណោះ នៅផ្ទះនោះមាណពម្នាក់ទើបនឹងមកពីរៀនមន្តឯនគរតក្កសិលា, ឯត្រូវនាំវាមក» ។ អាមាត្យនោះទទួលព្រះរាជបម្រើ ទៅហៅមាណពនោះថា «នែអ្នក!, ព្រះរាជាមាន

ព្រះរាជឱង្ការឱ្យហៅអ្នកឯង››, ហើយក៏នាំមាណពនោះទៅបង្គំថ្វាយ ។ ទើបព្រះរាជាត្រាស់សួរមាណពថា ‹‹អ្នកឯង ទើបមកពីរៀនសិល្ប ឯនគរតក្កសិលាឬ?›› -ព្រះករុណាថ្លៃវិសេស ។ អ្នកឯងឱ្យយើងរៀនសិល្បនោះផងបានឬទេ?; -សូមទ្រង់ព្រះមេត្តាប្រោស បាន, ប៉ុន្តែសូមព្រះអង្គគង់លើអាសនៈស្មើគ្នា ទើបរៀនបាន ។ ព្រះរាជាក៏ឱ្យមាណពអង្គុយស្មើនឹងព្រះអង្គ ទើបទ្រង់រៀនមន្តនោះ, ហើយទ្រង់ព្រះរាជទានប្រាក់មួយពាន់កហាបណៈ ។

គ្រានោះសេនាបតីម្នាក់ បានឱ្យប្រាក់ ១ ពាន់កហាបណដល់ខ្មាន់ព្រះកេស ហើយនិយាយថា ហើវេលាអ្នកឯងចំរើនព្រះមស្សុស្តេច, ត្រូវអ្នកឯងត្របះកាំបិតឱ្យយ៉ាងមុត ហើយកាត់ព្រះសុរង៍ស្តេចឱ្យសុគត់ទៅ, អ្នកឯងនឹងបានជាសេនាបតី, អញនឹងសោយរាជ្យជាស្តេច ។ ខ្មាន់ព្រះកេសក៏ទទួលព្រម; លុះដល់ថ្ងៃចម្រើនព្រះមស្សុ (កោរពុកចង្កា) ព្រះរាជាក៏ខ្មាន់ព្រះកេសយកទឹកអប់មកស្រព ហើយត្របះកាំបិត

យ៉ាងមុត ចាប់ព្រះនលាដ (ថ្ងាស) ផ្ងើយឡើងគិតថា អញនឹងកាត់ព្រះសុរងតែម្ដងឱ្យដាច់ ។ ខណៈនោះ ព្រះរាជានឹកឃើញមន្តព្រះអង្គ, ក៏ទ្រង់ស្វាធ្យាយឡើង, ស្រាប់តែខ្មាន់ព្រះកេសបែកញើសហូរចេញពីថ្ងាស, ហើយគិតថា ‹‹ច្បាស់ជាព្រះរាជាជ្រាបហើយ›› ក៏ភ័យណាស់ បោះកាំបិតចោលក្រាបទៀបព្រះបាទា ។ ព្រះរាជាមានព្រះរាជឱង្ការទៅនឹងខ្មាន់ព្រះកេសថា ‹‹នែខ្មាន់ព្រះកេសចង្រៃ! អាឯងមិនដឹងថាអញជាស្ដេចទេឬ? -បពិត្រព្រះសម្មតិទេព, សូមទ្រង់ព្រះមេត្តាប្រោសអភ័យទោសដល់ទូលព្រះបង្គំជាខ្ញុំ ។ អើអញអត់ទោសឱ្យ! ឯងកុំភ័យឡើយ, តែឯងប្រាប់អញឱ្យត្រង់ចុះ អ្នកណាបង្គាប់ឯង? ។ -បពិត្រព្រះសម្មតិទេព, លោកសេនាបតី បានឱ្យប្រាក់ ១ ពាន់កហាបណៈ បង្គាប់ឱ្យទូលបង្គំកាត់ព្រះសុរងព្រះអង្គ។ ព្រះរាជាទ្រង់សវនាការដូច្នោះហើយ ក៏ទ្រង់ព្រះតម្រិះថា ‹‹ឱអញ ! បានរួចរស់ជីវិត ដោយសារតែលោកអាចារ្យនោះតើ!››, ទើបទ្រង់ធ្វើបញ្ជាជនីយកម្មនិរទេសសេនាបតីនោះ

ចេញពីដែន ហើយទ្រង់ត្រាស់ហៅមាណពជាអាចារ្យនោះមក ទ្រង់តាំងជាសេនាបតីឡើង ។

មាណពកាលនោះ បានមកកើតជាចូឡបន្ថក, ព្រះរាជាបានមកកើតជាអានន្ទ, អាចារ្យទិសាបាមោក្ខ គឺអង្គតថាគតហ្នឹងឯង ។

បានជានាំរឿងនេះមក ដើម្បីបញ្ជាក់ឱ្យឃើញច្បាស់ថាសតិដែលបុគ្គលបានអប់រំល្អហើយ សូម្បីតែដេកលក់ក៏មិនភ្លេច គង់មានប្រយោជន៍ដល់បុគ្គលនោះៗ មិនខាន ។

ឯសម្បជញ្ញៈ ចែកជាបួនប្រការ គឺៈ

**១-សាត្ថកសម្បជញ្ញៈ** ដឹងទីឋានមានប្រយោជន៍, ដូចជាភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ដែលប្រកបដោយសម្បជញ្ញៈ គឺសេចក្តីពិចារណាឃើញ និងដឹងខ្លួនដោយសព្វគ្រប់នោះ, កាលបើគិតថានឹងទៅប្រទេសឯណានីមួយ នឹងបានទៅដោយប្រញាប់ប្រញាល់ តាមអំណាចចិត្តដែលគិតនោះក៏ទេ, ពិចារណាឱ្យដឹងថាមានប្រយោជន៍ ឬឥតប្រយោជន៍ជាមុន

ថា ‹‹ដែលអាត្មាអញទៅក្នុងទីនោះ តើនឹងមានប្រយោជន៍ដែរឬទេ?›› បើឃើញថា ទៅក្នុងទីនោះមានប្រយោជន៍ គឺនឹងបានទស្សនាឃើញអសុភឱ្យកើតត្រៃលក្ខណ៍ ប៉ុណ្ណេះជាដើមហើយទៅ ហៅថា ‹‹ដឹងទីឋានមានប្រយោជន៍›› ;

**២-សប្បាយសម្បជញ្ញៈ** ដឹងទីឋានជាទីសប្បាយ, ដូចជាភិក្ខុអ្នកប្រកបដោយសម្បជញ្ញៈ រមែងពិចារណារកដំណើរជាទីសប្បាយនិងមិនសប្បាយជាមុនថា ‹‹វេលាដែលអាត្មាអញទៅក្នុងទីនោះៗ តើនឹងបានអារម្មណ៍ជាទីសប្បាយដែរឬទេ?›› បើឃើញថានឹងយកអារម្មណ៍ឱ្យជាទីសប្បាយមិនបាន ក៏ឈប់បង្អង់; លុះបានពេលដែលកើតអារម្មណ៍ជាទីសប្បាយទើបទៅ យ៉ាងនេះជាដើម ហៅថា ‹‹ដឹងទីឋានជាទីសប្បាយ››;

**៣-គោចរសម្បជញ្ញៈ** ដឹងទីឋានជាទីគោចរ, ដូចជាភិក្ខុក្នុងពុទ្ធសាសនានេះ បានសិក្សាកម្មដ្ឋានណាមួយដែលមានអារម្មណ៍ជាទីគាប់ចិត្ត គឺសមគួរតាមចរិត ហើយកាន់យក

កម្មដ្ឋាននោះជាអារម្មណ៍គ្រប់វេលាដែលគោចរទៅរកចង្ក្រាន់ មិនបានឱ្យចិត្តនោះប្រាសចាកកម្មដ្ឋាន; ដំណើរដែលត្រាច់ទៅនោះ ហៅថា ‹‹ដឹងគោចរជាទីសប្បាយ››;

៤-អសម្មោហសម្បជញ្ញៈ ដឹងទីឋានមានសេចក្ដីមិនវង្វេង ដូចជាភិក្ខុអ្នកចម្រើនកម្មដ្ឋានក្នុងពុទ្ធសាសនានេះ ទោះបីលោកទៅណាមកណា លោកមិនដែលមានសេចក្ដីវង្វេងឡើយ, មុននឹងទៅមកលោកតែងគិតថា ‹‹អាត្មាអញឈានទៅមុខ›› ដូច្នេះជាដើម ក៏នឹកឃើញថា ‹‹ឱ! ឥឡូវនេះ វាយោ-ធាតុតាំងវិញ្ញត្តិឱ្យកើតឡើង គឺខ្យល់កម្រើកហើយតើ!›› ដូច្នេះ ជាមួយនឹងចិត្តដែលគិតថា ‹‹អញឈានទៅមុខ›› នោះឯង, ហើយគិតតទៅទៀតថា ‹‹ឱ! ឥឡូវនេះ វាងធ្អឹងដែលលោកសន្មតថា កាយនេះកាយនេះកំពុងឈានទៅមុខដោយអំណាចកម្រើកវាយោធាតុនិងកិរិយាចិត្តហើយ, គិតយ៉ាងនេះគ្រប់ឥរិយាបថទាំង ៤, ប៉ុណ្ណោះជាដើម ហៅថា ‹‹ដឹងទីឋានមានសេចក្ដីមិនវង្វេង›› ។

*សតិនិងសម្បជញ្ញៈទាំងពីរនេះ បើកើតឡើងព្រមគ្នាក្នុងវេលាណា ក៏រឹងរឹតតែទ្វេកម្លាំងច្រើនឡើង អាចកំចាត់សត្រូវគឺកិលេសដែលជាមេកងធំ គឺរាគៈ ទោសៈ មោហៈ ឱ្យអស់ទៅបាន, តែកិលេសទាំងនេះអស់ទៅហើយ ចិត្តក៏រមែងបរិសុទ្ធ ជ្រះថ្លាផូរផង់, ទុកជាមិនដាច់ជាសមុច្ឆេទប្បហានៈ ក៏គង់ជាតទង្គប្បហានៈ, កាលបើតទង្គប្បហានៈរឿយៗ ក៏រមែងក្លាយជាសមុច្ឆេទប្បហានៈទៅបាន ។ ព្រោះហេតុនោះហើយបានជាលោកចាត់ធម៌ទាំងពីរនេះថា ធម៌មានឧបការៈច្រើន ។*

---

## លោកបាលធម៌ ២ យ៉ាង (2)

**១-ហិរិ** *សេចក្តីខ្មាសបាប,*

**២-ឱត្តប្បៈ** *សេចក្តីខ្លាចបាប ។*

### អធិប្បាយ

សេចក្ដីខ្មាសបាប ក្នុងកាលដែលប្រព្រឹត្តសេចក្ដីអាក្រក់គ្រប់យ៉ាង មានសេចក្ដីស្អប់ស្អែងក្នុងចិត្ត ដូចជាឃើញលាមកដែលជិតដាមប្រឡាក់ដល់កាយ យ៉ាងនេះហៅថា ហិរិ ។

ហិរិ នេះចែកជា ៤ គឺ:

**១-ជាតឹ បច្ចវេក្ខិត្វា** ពិចារណាឃើញជាតិ;

**២-វយំ បច្ចវេក្ខិត្វា** ពិចារណាឃើញវ័យ;

**៣-សូរភាវំ បច្ចវេក្ខិត្វា** ពិចារណាឃើញសេចក្ដីក្លៀវក្លា;

**៤-ពាហុសច្ចំ បច្ចវេក្ខិត្វា** ពិចារណាឃើញខ្លួនជាពហុស្សូត ។

**ជាតឹ បច្ចវេក្ខិត្វា** ពិចារណាឃើញជាតិនោះ គឺពិចារណាឃើញថា ខ្លួនកើតមកជាមនុស្ស មានជាតិខ្ពង់ខ្ពស់មិនគួរទៅប្រព្រឹត្តធ្វើបាបកម្មផ្សេងៗ ដូចជាមនុស្សថោកទាប ឬសត្តិរច្ឆាននោះទេ, ពិចារណាដូច្នេះហើយ ក៏វៀរចាកនូវបាបកម្មនោះៗ ទៅ ។

**វយំ បច្ចវេក្ខិត្វា** *ពិចារណាឃើញវ័យនោះ គឺខ្លួនចូលក្នុងមជ្ឈិមវ័យឬបច្ឆិមវ័យហើយ ពិចារណាឃើញថា អាត្មាអញមានកន្ទង់ហើយ មិនគួរធ្វើបាបកម្មផ្សេងៗ ដូចជានៅក្មេងសោះ ពិចារណាឃើញយ៉ាងនេះហើយក៏លះបង់នូវបាបកម្មនោះៗ ទៅ ។*

**សូរតាវំ បច្ចវេក្ខិត្វា** *ពិចារណាឃើញសេចក្តីក្លៀវក្លានោះ គឺខ្លួនជាមនុស្សមានបណ្តាស័ក្តិ មានទ្រព្យសម្បត្តិឬក៏មានជាតិជាក្សត្រ ទៅកាន់ទីប្រជុំណាៗ តែងមានសេចក្តីក្លៀវក្លាអង់អាចជាងគេ មានគេកោតខ្លាចក្រាបសំពះច្រើន ក៏នឹកឃើញថា អាត្មាអញនេះគ្មានសីលហើយក៏រក្សាសីលឡើង ។*

**ពាហុស្សច្ចំ បច្ចវេក្ខិត្វា** *ពិចារណាឃើញថាខ្លួនជាពហុស្សូតនោះ គឺខ្លួនជាអ្នកចេះដឹងច្រើនជាងគេ ហើយទៅប្រព្រឹត្តធ្វើអំពើលាមកផ្សេងៗ នឹកដល់ការចេះដឹងនោះ ក៏អៀនខ្មាសមិនហ៊ានធ្វើអំពើលាកមនោះៗ ។*

ហិរិទាំង៤នេះជា **អជ្ឈត្តិកសមុដ្ឋាន** មានដែនកើតអំពីខ្លួនឯង; ជា **អត្តាធិប្បតេយ្យ** ប្រារព្ធយកខ្លួនជាធំ, **ជិគុច្ឆន-លក្ខណា** មានសេចក្ដីខ្ពើមនូវអំពើបាបជាលក្ខណៈ ឧបមាដូចស្ត្រីក្រមុំតែងអៀនខ្មាស យ៉ាងណា, ហិរិ ក៏យ៉ាងនោះដែរ ។

សេចក្ដីក្រែងខ្លាចដល់អំពើទុច្ចរិត គិតឃើញភ័យដែលកើតមកអំពីការធ្វើសេចក្ដីអាក្រក់ មានសេចក្ដីរួញព្រឺស្បែកដូចជាមនុស្សដែលខ្លាចសត្វអាសិរពិស មានចិត្តញាប់ញ័រតក់ស្លុតរន្ធត់ខ្លាចដូច្នោះហៅថាឱត្តប្បៈៗ នេះចែកទៅជា៤គឺៈ

**១-បរានុវាទភយៈ** ភ័យអំពីពាក្យតិះដៀលបុគ្គលដទៃ;

**២-អត្តានុវាទភយៈ** ភ័យអំពីការតិះដៀលខ្លួនឯងបាន;

**៣-ទុគ្គតិភយៈ** ភ័យខ្លាចធ្លាក់ទៅទុគ្គតិ;

**៤-ទណ្ឌភយៈ** ភ័យអំពីអាជ្ញារបស់ស្ដេច ។

ភ័យអំពីពាក្យបុគ្គលដទៃនោះ គឺខ្លួនឯងប្រព្រឹត្តអាក្រក់ដោយបាបកម្មណាមួយ ខ្លាចគេតិះដៀលហើយក៏មិនហ៊ានប្រព្រឹត្តអំពើអាក្រក់នោះៗ ហៅថា **បរានុវាទភយៈ**; ភ័យអំពី

ការតិះដៀលខ្លួនឯងនោះ គឺឃើញខ្លួនឯងដែលប្រព្រឹត្តខុសពីថ្ងៃមុនមក នឹកឃើញក្តៅក្រហាយអន្ទះអន្ទែងក្នុងចិត្តហើយក៏ខ្លាចអំពើអាក្រក់នោះមិនហ៊ានធ្វើ ហៅថា **អត្តានុវាទភយៈ**; ភ័យខ្លាចទៅកាន់ទុគ្គតិនោះ ព្រោះឃើញទោសក្នុងអបាយពិតប្រាកដ យ៉ាងនេះហៅថា **ទុគ្គតិភយៈ**; អំពីអាជ្ញារបស់ស្តេចនោះ គឺមិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ មានលួចគេជាដើម ព្រោះខ្លាចជាប់គុកច្រវាក់ ហៅថា **ទណ្ឌភយៈ** ។

ឱត្តប្បៈទាំង ៤ នេះជា **ពហិទ្ធាសមុដ្ឋាន** មានដែនកើតអំពីខាងក្រៅ, ជា **លោកាធិបតេយ្យ** ប្រារព្ធយកលោកជាធំ, **ឧត្តាសលក្ខណំ** មានសេចក្តីតក់ស្លុតនឹងអំពើបាបជាលក្ខណៈ ។

ហិរិនិងឱត្តប្បៈនេះ ប្រៀបដូចជាដែកពីរកំណាត់ មួយកំណាត់ត្រជាក់ទេ តែប្រឡាក់លាមក, មួយកំណាត់ទៀតក្តៅ; ដែលមួយកំណាត់ត្រជាក់តែប្រឡាក់លាមកនោះ បុគ្គលមិន

ហ៊ានកាន់ព្រោះខ្លើម ដូចជាហិរិ, ដែកមួយកំណាត់ក្ដៅនោះ បុគ្គលមិនហ៊ានកាន់ព្រោះខ្លាចក្ដៅ ដូចជាឱត្តប្បៈ ។

ធម៌ទាំងពីរប្រការនេះ បើបុគ្គលណាបានអប់រំហើយ, ធម៌ទាំងនោះអាចរក្សាបុគ្គលនោះ ឱ្យតាំងនៅក្នុងកម្មដ៏ល្អបាន, សមដូចពុទ្ធភាសិតសំដែងថា:

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ**

**ធម្មោ សុចិណ្ណោ សុខមាវហាតិ**

**ឯសានិសំសោ ធម្មេ សុចិណ្ណេ**

**ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។**

(ប្រែថា) ធម៌ហ្នឹងឯងរមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌, ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្ដីសុខ, កាលដែលបុគ្គលសន្សំធម៌ដោយប្រពៃហើយ រមែងបាននូវអានិសង្សបែបនេះមិនខាន, បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិឡើយ ។

ធម៌ទាំងពីរប្រការនេះ រមែងគ្រប់គ្រងរក្សាលោក (គឺពួកសត្វ) ឱ្យជាគណៈជាក្រុមនៅជាសុខសប្បាយ ដូចមាតាបិតា

រក្សាបុត្រធីតាឱ្យបានសេចក្ដីសុខ វៀរមិនឱ្យបៀតបៀនគ្នានិង គ្នាដូច្នោះ ។

---

## ធម៌ធ្វើឱ្យល្អ ២ យ៉ាង (3)

**១-ខន្តិ** សេចក្ដីអត់ធន់;

**២-សោរច្ច** សេចក្ដីស្ងប់ស្ងៀម ។

សេចក្ដីអត់ធន់ទ្រាំនឹងអក្កោសវត្ថុ ៩ យ៉ាងដែលមកប៉ះពាល់, អត់ធន់សេចក្ដីលំបាក, អត់ធន់សេចក្ដីឈឺចិត្ត, ជាលក្ខណៈរបស់ខន្តី ។

សេចក្ដីរីករាយស្រស់បស់ មានចិត្តល្អមិនសំដែងអាការៈឱ្យប្រាកដ ក្នុងកាលដែលអ្នកដទៃប្រមាថមើលងាយ ជាលក្ខណៈរបស់សោរច្ចៈ ។

សេចក្ដីល្អខាងក្រៅអាស្រ័យដោយសាប្រដាប់ប្រដាតាក់តែងរាងកាយ មានកែវពេជ្រនីលចិន្តាជាដើម, ក្នុងព្រះពុទ្ធ-សាសនានេះ មិនរាប់ថាល្អឡើយ, សេចក្ដីខាងក្នុងអាស្រ័យ

ធម៌ពីរប្រការនេះ ប្រចាំនៅក្នុងខន្ធសន្តានធ្វើឱ្យល្អដោយពិត, ក្នុងព្រះពុទ្ធសាសនានិយមរាប់អានថាជារបស់ល្អ ។

បានជាលោកចាត់ធម៌ទាំងពីរប្រការនេះ ថាជាធម៌ធ្វើឱ្យល្អនោះ, ព្រោះថាបើបុគ្គលណាមានធម៌ទាំងពីរប្រការនេះប្រចាំនៅក្នុងខន្ធសន្តានហើយ ទោះបីបុគ្គលនោះនៅទីណាកន្លែងណា រមែងបានសេចក្តីសុខ ចម្រើន បានកេរ្តិ៍ឈ្មោះល្អ និងអាចធ្វើអ្នកដទៃឱ្យល្អបានថែមទៀតផង ដូចយ៉ាងនាងឧត្តរា នាងមានធម៌ខន្តីនៅក្នុងសន្តាន នាងអាចញ៉ាំងនាងសិរិមាឱ្យបានសម្រេចមគ្គផលថែមទៀត, អាក្រក់នោះមិនមែនអាក្រក់តែឈ្មោះទេ សូម្បីរាងកាយក៏អាក្រក់ដែរ, ដូចមានក្នុងចូឡកម្មវិភង្គសូត្រសំដែងថា មនុស្សដែលមានរូបអាក្រក់មកពីមានសេចក្តីក្រោធ ដូចយ៉ាងនាងបញ្ចបាបាជាដើម នាងមានរូបអាក្រក់យ៉ាងនេះមកពីមិនមានខន្តី និងសោរច្ចៈ បានជាលោកចាត់ថាជាធម៌ធ្វើឱ្យល្អ គឺធ្វើឱ្យល្អក្នុងលោកនេះនិងលោមខាងមុខ; សមដូចពុទ្ធភាសិតសំដែងថា:

ខន្តិ បរមំ តបោតីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។

(ប្រែថា) *សេចក្តីអត់ធន់, សេចក្តីស៊ូទ្រាំ ជាតបៈដ៏ក្រៃលែង, អ្នកប្រាជ្ញទាំងឡាយរមែងសរសើរ ព្រះនិព្វានថាជាបរមសុខ, បព្វជិតបើជាអ្នកចង់បរូបឃាត បៀតបៀនគេ, មិនហៅថាសមណៈឡើយ ។*

*ខន្តីនេះបើទុកជាអ្នកណាធ្វើទុក្ខទោសដូចម្តេច ក៏ស៊ូទ្រាំមិនតបត ដូចយ៉ាងរឿងខន្តិវាទីតាបសសំដែងថា:*

**អតីតេ ពារាណសិយំ ពោធិសត្តោ កុណ្ឌោ នាម ព្រាហ្មណោ ហុត្វា ។បេ។ ឯវំ វត្វា តាបសោ តំ ធិរសមេវ តត្ថេវ កាលមកាសិ ។**

*ក្នុងកាលដែលកន្លងទៅហើយ ព្រះពោធិសត្វរបស់យើងបានយកកំណើតជាព្រាហ្មណ៍ព្រះនាមកុណ្ឌៈ ក្នុងក្រុងពារាណសី បានចេញទៅបួសជាតាបសឫសី នៅអាស្រ័យ*

នឹងភ្នំហិមពាន្តអស់កាលដ៏យូរ ក៏ត្រឡប់មកកាន់ក្រុងពារាណសី ដើម្បីឆាន់វត្ថុមានរសជូរនិងវត្ថុមានរសប្រៃ សម្រេចការនៅក្នុងឧទ្យានរបស់ព្រះរាជា ។ ថ្ងៃមួយ ព្រះរាជាព្រះនាមកលាពុ ទ្រង់សោយសុរារួចហើយក៏នាំពួកស្រីៗ ជាបរិវារទៅក្រសាលក្នុងឧទ្យាន ទ្រង់ផ្ទំលើភ្លៅស្ត្រីរបាំម្នាក់ដែលជាគាប់ព្រះរាជហឫទ័យ ។ ចំណែកពួកស្ត្រីដទៃៗ កាលបើដឹងថាព្រះរាជាទ្រង់ផ្ទំលក់ហើយ ដូច្នោះក៏នាំគ្នារត់ចោលអស់ហើយនាំគ្នាចូលទៅក្នុងឧទ្យាន ក៏បានឃើញព្រះពោធិសត្វដែលកំពុងគង់ក្រោមដើមរាំងមានផ្ការយោនរយាន ហើយនាំគ្នាធ្វើវន្ទនាការអង្គុយស្តាប់ធម៌ក្នុងទីនោះ ។ ចំណែកឯព្រះរាជា កាលបើតើនពីផ្ទំហើយ ទ្រង់ទតរកស្ត្រីទាំងនោះមិនឃើញដូច្នោះ ក៏មានព្រះទ័យទោមនស្សខ្លាសចំពោះស្ត្រីទាំងនោះពន់ពេក ហើយក៏កាន់ព្រះខ័ននៅដៃទ្រង់យាងទៅក្នុងឧទ្យាននោះ ។ លំដាប់នោះ ស្ត្រីទាំងឡាយបានឃើញព្រះរាជាទ្រង់ស្តេចយាងចូលមកដូច្នោះ ក៏នាំគ្នាស្ទុះទៅដណ្តើម

យកព្រះខ័នពីព្រះហស្តព្រះរាជា ។ ចំណែកខាងព្រះរាជាក៏ចូលទៅសួរខន្តិវាទិតាបសថា «បពិត្រសមណៈ, លោកឈ្មោះខន្តិវាទិឬ?» តាបសថ្វាយព្រះពរថា «បពិត្រមហារាជ, អាត្មាភាពឈ្មោះខន្តិវាទិ» ។ ព្រះរាជាទ្រង់ត្រាស់សួរថា ខន្តិវាទិ តើដូចម្តេច? តាបសថ្វាយព្រះពរថា «បុគ្គលណាមិនមានចិត្តខឹងចំពោះជនទាំងឡាយដទៃ ដែលគេជេរ ឬប្រហារ ឬក៏ប្រទេច បុគ្គលនោះឈ្មោះថា ខន្តិវាទី» ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ព្រះនាមតាបសដូច្នោះហើយ ក៏មានព្រះរាជឱង្ការហៅចោរឃាតក៏ម្នាក់ដោយព្រះបន្ទូលថា «យើងបានឃើញតាបសមានខន្តីធម៌ម្នាក់, បើដូច្នោះមានតែអ្នកទៅប្រហារតាបសនោះលងមើល?» ហើយក៏ចាប់ទាញឱ្យដួលចុះលើផែនដី ហុចរំពាត់ផ្តៅទៅចោរឃាតក៏ដោយព្រះបន្ទូលថា «ចូរអ្នកប្រហារតាបសនេះ ពីខាងមុខពីរពាន់រំពាត់ ខាងក្រោយពីរពាន់រំពាត់មើល?» ចោរឃាតក៏ក៏ធ្វើតាមព្រះបង្គាប់ ។ ទើបព្រះរាជាទ្រង់ត្រាស់សួរថា «លោកឈ្មោះខន្តិវាទីឬ? -ថ្វាយ

ព្រះពរមហារាជ, អាត្មាភាពជាឈ្មោះខន្តិវាទី ។ ហើយថ្វាយព្រះពរតទៅទៀតថា ចុះព្រះអង្គសម្គាល់ថា ខន្តីមាននៅក្នុងចន្លោះស្បែកអាត្មាឬ? ខន្តីមិនមានក្នុងចន្លោះស្បែកនោះទេ មាននៅក្នុងហឫទ័យអាត្មាទេតើ ! ។ ព្រះរាជាប្រើចោរឃាតក៍ឱ្យកាត់ដៃ-ជើងតាបសទៀត ហើយត្រាស់សួរម្តងទៀត; តាបសថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាភាពឈ្មោះខន្តិវាទី; ចុះព្រះអង្គសំគាល់ថា ដៃជើងរបស់អាត្មាឈ្មោះខន្តិ-វាទីឬ? ខន្តីមិនមែននៅក្នុងដៃនិងជើងនោះទេ នៅក្នុងហឫ-ទ័យនៃអាត្មាទេតើ! ព្រះរាជាក៏ប្រើចោរឃាតក៍ឱ្យកាច់ច្រមុះនិងច្រចៀកតាបសនោះ ហើយត្រាស់សួរម្តងទៀត តាបសនៅតែមានពុទ្ធដីកាដូចមុន ។ ព្រះរាជាខ្ញាល់ណាស់ ដោយទាល់តម្រិះរកធ្វើតាបសខ្ញាល់មិនឃើញ (តាមពិតបើទុកជាព្រះរាជាធ្វើដូចម្តេចទៀតក៏លោកមិនខឹងឡើយ, ព្រោះតែលោកមានធម៌ខន្តីនៅក្នុងសន្តាន) ហើយព្រះរាជាក៏ស្ទុះទៅទាត់តាបសត្រង់ដើមទ្រូង ហើយដើរចៀសចេញទៅ ។ ព្រះរាជា

*អង្គនោះចេញចាកពីទីនោះទៅមិនឆ្ងាយប៉ុន្មាន ក៏ព្រះធរណី ស្រូបទាំងរស់ស្លាប់ទៅកើតក្នុងនរកអវិចី ។*

*ជនទាំងឡាយមានសេនាបតីជាដើម កាលបើឮដំណឹង ថា ព្រះរាជាចូលកាន់ផែនដី ដោយកម្មដែលខ្លួនបានប្រទូស្ត ចំពោះតាបសដែលជាបុគ្គលមិនប្រទូស្តតបដូច្នោះ ក៏មានចិត្ត ខ្សឹកខ្សួលស្រណោះនឹកដល់តាបស ដែលជាបុគ្គលមានខ្លឹមធម៌ នៅក្នុងសន្តាន ហើយចូលទៅក្រាបថ្វាយបង្គំទូលសួរតាបស ថា បពិត្រតាបសដ៏ចំរើន ប្រសិនបើជនទាំងឡាយ ដូចជា ស្តេចព្រះនាមកលាពុជាដើម ប្រទូស្តចំពោះលោកម្ចាស់, តើ លោកម្ចាស់ មានហឫទ័យខឹងចំពោះជនទាំងនោះទេឬ? តាបសក៏ពោលពាក្យថា:*

**យោ មេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ**
**ចិរំ ជីវតុ សោ រាជា ន ហិ កុជ្ឈន្តិ មាទិសា ។**

(ប្រែថា) ព្រះរាជាអង្គណា បានកាត់ដៃ-ជើងត្រចៀកច្រមុះរបស់អាត្មា ព្រះរាជាអង្គនោះ ចូររស់នៅអស់កាលដ៏យូរចុះ; ម្នាលអ្នកនិរទុក្ខ អាត្មាមិនខឹងឡើយ ។

តាបសគ្រាន់តែពោលគាថានចប់ភ្លាម ក៏ធ្វើកាលកិរិយាទៅក្នុងថ្ងៃនោះឯង ។

បានជានាំនិទានមកនេះ ដើម្បីបញ្ជាក់ឱ្យឃើញច្បាស់ប្រាកដថា បុគ្គលដែលមានខន្តីធម៌នៅក្នុងខន្ធសន្ដាន បើទុកជាបុគ្គលណាមួយធ្វើទុកទោសដូចម្ដេច ក៏មិនមានចិត្តប្រទូស្តតបចំពោះបុគ្គលអ្នកធ្វើទុក្ខទោសនោះឡើយ ។

ម្យ៉ាងទៀត ដូចជាបុគ្គលអន្ធពាលក្នុងលោក អប្បឥតប្រាជ្ញា បើសិនជាបុគ្គលណាប្រទូស្តចំពោះខ្លួន តែខ្លួនជាបុគ្គលមិនចេះឧបាយកាលនឹងធ្វើឱ្យគេចាលចាញ់វិញហើយបែរជាគិតថា អញមិនប្រទូស្តតបចំពោះបុគ្គលបែបនេះទេ, ការអត់សង្កត់កំហឹងរបស់បុគ្គលបែបនេះ មិនហៅថាខន្តីទេ ដូចសុភាសិតថា «ខន្តីកុំខន្តីទាល់គំនិត ខន្តីធម៌ពិតមិនដូច្នោះ

ណា ខន្តីទាល់គំនិតឥតប្រាជ្ញា ខន្តីនេះហៅថា មោឃ-មោហៈ ។ ឯបុគ្គលដែលមានខន្តីធម៌ពិត ដូចជាខន្តិវាទីតាបសនោះឯង; ខន្តីយ៉ាងនេះ ហៅថា អធិវាសនខន្តី, សមដូចពុទ្ធភាសិតថា:

**ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ**
**ខន្តិ ពលំវ យតីនំ ខន្តិ ហិតសុខាវហា ។**

(ប្រែថា) ខន្តីជាអង្គាររបស់នៃធីរៈ ខន្តីជាតបៈនៃតាបស ខន្តីជាពលយោគីទាំងអស់ ខន្តីជារបស់កើតហិតសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**
**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ ។**

(ប្រែថា) អ្នកកាន់ខន្តី តែមានមេត្រី នឹងលាភយសក្តីសុខធម្មតាអ្នកកាន់ខន្តីជាទីបិយា មនាបានៃទេវតាមនុស្ស ។

**អត្តនោបិ បរេសញ្ច អត្ថាវហាវ ខន្តិកោ**
**សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ ។**

(ប្រែថា) អ្នកកាន់ខន្តីរមែងកើតអត្ត ដល់ខ្លួននិងបរិស័ទនានា កាន់ខន្តីឈ្មោះថាសាងមគ៌ា ទៅកាន់សួគ៌មហានិព្វាន ។

ខន្តីនិងសោរច្ចៈជាគូនឹងគ្នា បើនិយាយខន្តី ដូចជានិយាយសោរច្ចៈដែរ ហេតុនេះ មេធាវីជាបណ្ឌិត គួរជ្រាបបានតាមរឿងដែលពោលមកហើយនោះចុះ ។

---

## បុគ្គលរកបានដោយកម្រ ២ យ៉ាង (4)

**១-បុព្វការី** អ្នកធ្វើឧបការៈមុន;

**២-កតញ្ញូ កតវេទី** អ្នកដឹងឧបការៈដែលលោកធ្វើហើយធ្វើតបវិញ ។

**អធិប្បាយថា:**

បុព្វការី បានដល់អ្នកដែលបានផ្ដួចផ្ដើមទំនុកបម្រុងមុន ឈ្មោះថា បុព្វការីៗ នេះមាន ៤ យ៉ាងគឺ: មាតាបិតាជាបុព្វការីរបស់បុត្រធីតា ១, គ្រូឧបជ្ឈាយាចារ្យជាបុព្វការីរបស់អន្តេវាសិក ១, ព្រះរាជាជាបុព្វការីរបស់ប្រជារាស្ត្រ ១, ព្រះសម្ពុទ្ធជា

បុព្វការីរបស់ពុទ្ធបរិស័ទ ១, ម៉្យាងទៀត អ្នកដទៃទេ ប៉ុន្តែគេបានទំនុកបម្រុងខ្លួនមុន ក៏ហៅថាបុព្វការីបានដែរ ។

បានជាលោកចាត់ថារកបានដោយកម្រនោះ គឺបុព្វការីទាំងនោះ កម្រនឹងបានជួយទំនុកបម្រុងទៅតាមគន្លងធម៌ ដូចយ៉ាងមាតាបិតាមានចិត្តស្នេហាដល់បុត្តធីតាជាទីបំផុត តែមិនសង្គ្រោះទៅតាមសង្គហធម៌ទាំង ៥ ម៉្លោះហើយកូននោះក៏ប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ បានសេចក្តីទុក្ខទៅក្នុងខាងមុខ, ចំណែកគ្រូទំនុងបម្រុងកូនសិស្សមិនសូវស្មោះត្រង់ ច្រើនតែប្រកបដោយអគតិធម៌ទាំង ៤ មិនសង្គ្រោះទៅតាមសង្គហធម៌ដែលត្រូវសង្គ្រោះនោះៗ, ចំណែកខាងព្រះរាជាច្រើនតែមិនប្រកបដោយទសពិធរាជធម៌ ១០ ប្រការ, ចំណែកអ្នកដទៃ បើជួយទំនុកបម្រុងគិតតែទារយកប្រយោជន៍ផ្ទាល់ខ្លួន កម្រនឹងមានអ្នកណាជយទំនុងបម្រុងដោយស្មោះត្រង់, បុព្វការីទាំងនេះមកពីតណ្ហាគ្របសង្កត់ បានជាលោកចាត់ថារកបាន

ដោយកម្រ ។ លើកលែងតែព្រះសម្ពុទ្ធ និងព្រះអរហន្តជាព្រះខីណាស្រពចេញ ។

ចំណែកកតញ្ញូ កតវេទី បានជាចាត់ថាក្រដែរនោះ ព្រោះមានអវិជ្ជាគ្របសង្កត់មិនឱ្យដឹងឧបការគុណ ដែលអ្នកដទៃបានធ្វើដល់ខ្លួននោះៗ ។ ទុកជាឱ្យផែនដីសោយរាជ្យក៏បុគ្គលជាអកតញ្ញូនោះនៅតែរករឿងរកទោសផ្សេងៗ បានជាលោកចាត់ថា រកបានដោយកម្រ ។

ចប់ទុកៈពួក ២

---

## តិកៈពួក ៣ (5)

ព្រះពុទ្ធ ១, ព្រះធម៌ ១, ព្រះសង្ឃ ១ ។

១-លោកអ្នកប្រដៅពួកជនឱ្យប្រតិបត្តិល្អដោយកាយវាចា ចិត្ត តាមធម្មវិន័យ ហៅថា ព្រះពុទ្ធ;

២-ធម្មវិន័យ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហៅថា ព្រះធម៌;

៣-ពួកជនដែលបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហើយប្រតិបត្តិល្អតាមធម្មវិន័យ ហៅថា ព្រះសង្ឃ ។

**អធិប្បាយថា:**

**រតនៈ** ប្រែថា កែវ ដែលជាវត្ថុនាំឱ្យកើតសេចក្ដីត្រេកអរ, តែរតនៈក្នុងទីនេះសំដៅយក ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ព្រោះអាចធ្វើឱ្យកើតសេចក្ដីជ្រះថ្លាត្រេកអរ ដល់អ្នកដែលជ្រះថ្លា អ្នកដែលដល់នូវរតនៈទាំង ៣ នេះជាទីពឹងទីរលឹកហើយ រមែងរួចចាកទុក្ខទាំងពួង ។

បណ្ដាឈ្មោះដែលពីរោះទាំងប៉ុន្មាន គ្មានឈ្មោះណាពីរោះល្អគួរយកមកប្រៀបឱ្យស្មើ ។ ក្នុងលោកនេះ មានតែកែវជាវត្ថុមានអំណាចអាចសម្រេចប្រយោជន៍យ៉ាងធំ ជាវត្ថុថ្លៃឧត្តម ជាឈ្មោះដ៏ពីរោះសមគួរល្មមនឹងហៅបាន, បណ្ដាកែវមានក្នុងលោកទាំងប៉ុន្មាន រួមហៅឈ្មោះថារតនៈ ព្រោះជារបស់មានតម្លៃ ថ្លៃបំផុតមានអំណាចធ្វើសេចក្ដីត្រេកអរឱ្យកើតដល់មនុស្សនិងទេវតា បានសម្រេចដូចប្រាថ្នាក្នុងលោកនេះ ។

ព្រោះហេតុនោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយ លោកលើកយកបទថា: ពុទ្ធោ ធម្មោ សង្ឃោ ទាំងបីបទនេះ មកឱ្យឈ្មោះថា រតនៈ ព្រោះជាគុណខ្ពស់បំផុត មានអំណាចអាចញ៉ាំងសម្បត្តិទាំងបី ឱ្យសម្រេចដល់មនុស្សនិងទេវតា សមគួរដល់សេចក្តីប្រាថ្នារបស់ខ្លួនផង, ដូចពាក្យដែលលោកពោលទុកក្នុងរតនសូត្រថា **រតនំ បណីតំ** ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃទាំង ៣ នេះ ជាកែវមានតម្លៃដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តម បញ្ចង់ អស់ពីចិត្ត លើកលែងកែវណាៗ, **អប្បមាណោ ពុទ្ធោ** ព្រះពុទ្ធគ្មានបុគ្គលណាប្រមាណបាន, **អប្បមាណោ ធម្មោ** ព្រះធម៌គ្មានបុគ្គលណាប្រមាណបាន, **អប្បមាណោ សង្ឃោ** ព្រះសង្ឃគ្មានបុគ្គលណាប្រមាណបាន ។

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គ្មានវត្ថុអ្វីធ្វើជាខ្នាតប្រមាណបាន ឬប្រមាណថាតូចធំប៉ុណ្ណេះប៉ុណ្ណោះដូច្នោះក៏មិនបាន ដូចមានរឿងនិទានថា: កាលព្រះពុទ្ធអង្គត្រាស់ដឹងឡើងក្នុងលោក មានកិត្តិសព្ទដ៏ខ្លង់ខ្លស់ពីរោះខ្ទរខ្ទាយ ផ្សាយទូទៅដល់

មនុស្សនិងទេវតា សឹងតែនាំគ្នាមកនមស្សការថ្វាយបង្គំគោរពបូជាមិនដែលដាច់ ។ កាលនោះ រាហូអសូរិន្ទជាសេនាបតីនៃព្រះបាទវេបចិត្តិ សោយរាជ្យសម្បត្តិ នៅក្នុងនគរចិត្រាសូរក្រោមបាតភ្នំព្រះសុមេរុ, **រាហុ ភិរ អសុរិន្ទោ** ដូចបានឮថា: រាហូជាធំក្រៃលែងអសុរទាំងឡាយ **ចត្តារិ យោជនសហស្សានិ អដ្ឋ ច យោជនសតានិ ឧច្ចោ** រាហូអសុរិន្ទ កំពស់ ៤ ពាន់ ៨ រយយោជន៍, **ពាហន្តរមស្ស ទ្វាទស យោជនសតានិ** ចន្លោះដើមដៃប្រវែង ១ ពាន់ពីររយយោជន៍, **ថនន្តរេន ឆ យោជនសតានិ** ចន្លោះដោះ គឺពីដោះម្ខាងទៅដោះម្ខាង ៦ រយយោជន៍, **ហត្ថតលបាទតលានិ បុថុលតោ តីណិ យោជនសតានិ** បាតដៃបាតជើងទំហំ ៣០០ យោជន៍, **អង្គុលិបព្វានិ បណ្ណាស យោជនានិ** ថ្នាំងម្រាមដៃមួយៗ ប្រវែង ៥០ យោជន៍, **មត្ថកន្តរំ បណ្ណាស យោជនំ** ចន្លោះចិញ្ចើម គឺពីចិញ្ចើមម្ខាងទៅម្ខាង ៥០ យោជន៍, **មុខំ ទ្វិយោជនសតំ** វង្វះមាត់ ២០០ យោជន៍, **តិយោជនសតំ**

**គម្ពីរំ** ជម្រៅមាត់ ៣០០ យោជន៍, **តិយោជនសតំ បរិមណ្ឌលំ** ជុំវិញវង្វង់មាត់ ៣០០ យោជន៍, **គិវា តិយោជនសតំ** កប្រវែង ៣០០ យោជន៍, **នលាដំ តិយោជនសតំ** ថ្ងាសទំហំ ៣០០ យោជន៍, **សីសំ នវ យោជនសតំ** ក្បាលទំហំ ៩០០ យោជន៍ ។ រាហូអសុរិន្ទនោះគិតថា «អញខ្ពស់ណាស់ បើនឹងទៅមើលព្រះសាស្ដា ក៏លំបាកឱនមើល» គិតដូច្នេះ ក៏មិនបានទៅមើល ។ ក្នុងថ្ងៃមួយ រាហូអសុរិន្ទបានឮកិត្តិសព្ទសរសើរអំពីព្រះដ៏មានបុណ្យម្ដងទៀត ហើយក៏គិតថា «អញនឹងក្រឡេកមើលព្រះមានព្រះភាគធ្វើម្ដេចឱ្យងាយស្រួលហ្ន៎!» គិតដូច្នោះក៏សំដៅទៅវិហារជេតពន ដើម្បីនឹងក្រឡេកមើលព្រះសាស្ដា ។ ព្រះពុទ្ធអង្គទ្រង់ជ្រាបហេតុនោះក្នុងព្រះទ័យព្រះអង្គហើយ ក៏ទ្រង់ព្រះតម្រិះថា «តថាគតនឹងឱ្យរាហូអសុរិន្ទមើលបានងាយយ៉ាងណា, បើតថាគតឈរឱ្យមើល ក៏ខ្ពស់ព្រោះតែឈរ ឬតថាគតនឹងដើរនិងអង្គុយក៏គង់នៅខ្ពស់ ព្រោះតែតថាគតដើរ

និងអង្គុយ, ណ្ហើយចុះ តថាគតសឹងឱ្យមើលវិញទំនងជាង›› ព្រះអង្គទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏មានព្រះពុទ្ធដីកាទៅនឹងព្រះអានន្ទថា អានន្ទ ចូរអ្នកយកគ្រែទៅដាក់ខាងក្រៅកុដិតថាគតនឹងសិងសម្រាកព្រះកាយបន្តិច ។ ព្រះអានន្ទក៏ធ្វើតាមព្រះពុទ្ធដីកា ហើយព្រះអង្គទ្រង់ផ្ទំផ្អៀងបែរស្តាំដាក់ឆ្វេងលើ ផ្ទំចាំរាហូអសុរិន្ទនៅលើគ្រែនោះ ។ លំដាប់នោះ រាហូអសុរិន្ទ ក៏ចូលទៅដល់តាំងងើយក្រឡេកមើលព្រះមានព្រះភាគ ដូចជាក្រឡេកមើលព្រះចន្ទនៅកណ្តាលនភាល័យ ។ ព្រះអង្គមានព្រះពុទ្ធដីកាសួរថា ហៃរាហូអសុរិន្ទ! អ្នកឯងមកមានការអ្វី? រាហូអសុរិន្ទក្រាបទូលថា ខ្ញុំព្រះអង្គគិតថា បើមករកព្រះអង្គក្រែងពិបាកឱនមើល បានជាខ្ញុំព្រះអង្គមិនដែលមករកព្រះអង្គម្តងសោះ ។ ព្រះអង្គត្រាស់ថា ‹‹ម្នាលរាហូអសុរិន្ទ! បារមីទាំងឡាយមានទានជាដើម តថាគតមិនឱនមុខផ្កាប់ចុះក្រោមហើយបំពេញទេ; ទានតថាគតងើបមុខឡើងហើយទើបឱ្យ; ម្នាលរាហូអសុរិន្ទ! អ្នកចូរដឹងយ៉ាងនេះឯង

រាហុអសុរិន្ទក៏កើតសេចក្ដីជ្រះថ្លា បានដល់នូវត្រៃសរណ-គមន៍ក្នុងថ្ងៃនេះរៀងរហូតដល់មកសព្វថ្ងៃនេះ ។ ព្រះមានព្រះភាគជា **អប្បមាណោ** គ្មានគុណអ្វីជាខ្នាតប្រមាណបាន, ព្រះសង្ឃជា **អប្បមាណោ** គ្មានបុគ្គលណាជាខ្នាតប្រមាណបាន ។ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំង ៣ នេះ ឈ្មោះថារតនៈ ជាកែវមានតម្លៃថ្លៃបំផុតនឹងរកវត្ថុអ្វីមកប្រៀបផ្ទឹមមិនបាន ជាសរណៈជាទីពឹងទីរឭក របស់មនុស្សនិងទេវតាយ៉ាងប្រសើរខ្ពស់បំផុត ។

សំដែងមកតាមអត្ថនោមត្យាធិប្បាយប៉ុណ្ណោះ ក៏សមរម្យដល់សរណគមន៍, សប្បុរសអ្នកបានស្ដាប់បានឃើញអាចដឹងសេចក្ដីអស្ចារ្យក្នុងបទថា ពុទ្ធោ ធម្មោ សង្ឃោ និងបានតាំងចិត្តគំនិតឱ្យជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ កាន់យកនូវទីពឹងទីលឹករបស់ខ្លួន និងបានជាពុទ្ធបរិស័ទក្នុងព្រះពុទ្ធសាសនាតរៀងទៅ ឈ្មោះថាជាអ្នកមានទីពឹងផ្អែកយ៉ាងប្រសើរ ។

---

# គុណរបស់ព្រះរតនៈ ៣ យ៉ាង (6)

*១-ព្រះពុទ្ធ ទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គជាមុន ហើយប្រដៅអ្នកដទៃឱ្យដឹងតាមផង;*

*២-ព្រះធម៌រក្សាអ្នកប្រតិបត្តិ មិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់;*

*៣-ព្រះសង្ឃ លោកអ្នកប្រតិបត្តិល្អតាមពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយប្រដៅអ្នកដទៃឱ្យធ្វើតាមផង ។*

**អធិប្បាយថា:**

*ការដឹងនូវអរិយសច្ចទាំង ៤ គឺ ទុក្ខសច្ច ១, សមុទសច្ច ១, និរោធសច្ច ១, មគ្គសច្ច ១ ហៅថា ត្រាស់ដឹងប្រពៃ ព្រះអង្គមិនមានគ្រូអាចារ្យណានឹងប្រៀនប្រដៅ ទ្រង់ជ្រួតជ្រាបដោយព្រះបញ្ញាញាណរបស់ព្រះអង្គឯង ហៅថា ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ហើយទើបប្រដៅអ្នកដទៃឱ្យត្រាស់ដឹងតាមក្នុងសច្ចធម៌ទាំង ៤ យ៉ាងនោះ ។*

*ព្រះធម៌តែងរក្សាគ្រប់គ្រងអ្នកប្រតិបត្តិ មិនធ្លាក់ទៅកាន់ទីអាក្រក់ សមដូចពុទ្ធភាសិតសំដែងថា:* **ន ទុគ្គតឹ គច្ឆតិ**

**ធម្មចារី** បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិភព ឡើយ ។

ស្ថានទីអាក្រក់ក្នុងបច្ចុប្បន្ន បានដល់គុកច្រវាក់ជាដើម ភពខាងមុខបានដល់ នរក ប្រេត អសុរកាយ និង តិរច្ឆាន ។

ព្រះធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង និងបញ្ញត្តទុក ព្រះសង្ឃលោកអ្នកប្រតិបត្តិមិនឱ្យខុសផ្លូវធម្មវិន័យនោះ ហើយប្រៀនប្រដៅអ្នកដទៃឱ្យប្រតិបត្តិតាម ដូច្នោះផង ។

---

## អាការៈ ដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង (7)

**១-អភិញ្ញាយ:** ទ្រង់ប្រដៅដើម្បីឱ្យអ្នកស្តាប់ដឹងពិតឃើញពិត ក្នុងធម៌ដែលគួរដឹងគួរឃើញ;

**២-សនិទានៈ** ទ្រង់ប្រដៅមានហេតុ កាលណាអ្នកស្តាប់ត្រិះរិះតាមរមែងឃើញពិតបាន;

**៣-សប្បាដិហារៈ** ទ្រង់ប្រដៅជាអស្ចារ្យ គឺកាលអ្នកស្ដាប់ប្រតិបត្តិតាម រមែងសម្រេចប្រយោជន៍តាមគួរដល់សេចក្ដីប្រតិបត្តិ ។

**អធិប្បាយថា៖**

ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងបើកចំហ មិនមានបិទបាំង អាស្រ័យព្រះមហាករុណាទិគុណ ប្រព្រឹត្តទៅក្នុងពពួកសត្វទាំងឡាយ ទាំងព្រះហឫទ័យប្រៀនប្រដៅសត្វមែនៗ ដើម្បីឱ្យដឹងពិត ឃើញពិត ក្នុងធម៌ដែលគួរដឹង គួរឃើញ គឺសុចរិតជាកិច្ចគួរបំពេញ ទុច្ចរិតជាកិច្ចគួរលះបង់ ។

ព្រះអង្គទ្រង់ប្រៀនប្រដៅ មានហេតុផលល្មមគ្រប់គ្រាន់ដល់អ្នកស្ដាប់ហើយ ពិចារណាត្រិះរិះតាមរមែងឃើញពិតដឹងពិតតាមធម៌ដែលខ្លួនពិចារណានោះៗ ។ អ្នកប្រតិបត្តិតាមធម៌ដែលព្រះអង្គទ្រង់ប្រដៅនោះ រមែងទទួលផលប្រយោជន៍ដ៏សមគួរដល់សេចក្ដីប្រតិបត្តិ តាំងអំពីជានទាបរហូតដល់ជាន់ខ្ពស់ជាទីបំផុត គឺបានវិមុត្តិជាអកាលិកោ ជាធម៌ឱ្យផល

មិនមានកំណត់កាលវេលា ត្រូវទទួលក្នុងវេលាដែលខ្លួនបាន ប្រតិបត្តិនោះ ។

## ឱវាទរបស់ព្រះពុទ្ធ ៣ យ៉ាង (8)

**១-សព្វបាបស្ស អករណំ** មិនឱ្យធ្វើនូវបាបទាំងពួង គឺឱ្យ វៀរចាកទុច្ចរិតប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត;

**២-កុសលស្សូបសម្បទា** ឱ្យញ៉ាំងកុសលឱ្យដល់ព្រម គឺ ឱ្យប្រកបសុចរិតប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត;

**៣-សចិត្តបរិយោទបនំ** ឱ្យជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់ ចាកគ្រឿងសៅហ្មងចិត្តមានលោភៈ ទោសៈ មោហៈជាដើម ។ អធិប្បាយថាៈ

អំពើបាបនោះ បានដល់អកុសលធម៌ទាំងអស់ គឺ អកុសលកម្មបថ ១០, អកុសលមូល ៣, អកុសលចិត្ត ១២, អកុសលចេតសិក ១៤, ឈ្មោះថា ‹‹បាប››, អំពើបាបទាំងអស់ នេះហើយដែលព្រះសម្មាសម្ពុទ្ធហាមមិនឱ្យធ្វើ ។

ពាក្យថា «ញ៉ាំងកុសលធម៌ឱ្យដល់ព្រម» ដូច្នេះគឺៈ កុសលកម្មបថ ១០, កាមាវចរកុសល ៨, រូបាវចរកុសល ៥, អរូបា-វចរកុសល ៤, លោកុត្តរកុសល ៤ រហូតដល់ព្រះអរហត្ត ឈ្មោះថា «ញ៉ាំងកុសលធម៌ឱ្យដល់ព្រម» ។

ពាក្យថា «ឱ្យជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់» គឺឱ្យប្រាស-ចាកនីវរណធម៌ទាំង ៥ និងឧបក្កិលេសធម៌ ១៦ ឱ្យស្អាតពីខន្ធសន្ដាន ឈ្មោះថា «ជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់» ។

ការមិនធ្វើអំពើអាក្រក់គ្រប់យ៉ាង គឺវៀរចាកទុច្ចរិតហើយប្រកបដោយសុចរិត បានដល់ការដែលបំពេញបុណ្យ, បានដល់ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ចាកកិលេសជាគ្រឿងសៅ-ហ្មង មានលោភៈ ទោសៈ មោហៈជាដើម; ពាក្យទាំង ៣ ប្រការនេះ រួមហៅថាព្រះពុទ្ធោវាទ; ពុទ្ធោវាទនេះ ព្រះអង្គទ្រង់ប្រៀនប្រដៅវេនេយ្យសត្វ តាំងពីបឋមពោធិកាលរហូតដល់បច្ឆិមពោធិកាល បើគិតជាវស្សាបាន ៤៥, ព្រះពុទ្ធោវាទ

ឯទៀតៗ មានតិចច្រើនត្រឹមណា ជ្រៅទូលាយត្រឹមណា ក៏គួររួបរួមប្រមូលចុះក្នុងពុទ្ធោវាទ ៣ នេះទាំងអស់ ។

មួយទៀត ឱវាទទាំង ៣ នេះ បានដល់ត្រៃសិក្ខាទាំង ៣ គឺសីល, សមាធិ, បញ្ញា ។

## ទុច្ចរិត ៣ យ៉ាង (9)

១-កាយទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយកាយ;

២-វចីទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយវាចា;

៣-មនោទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយចិត្ត ។

### អធិប្បាយថា:

កាយទុច្ចរិត គឺអំពើដែលប្រព្រឹត្តអាក្រក់ដោយកាយមាន ៣ យ៉ាងគឺ: សម្លាប់សត្វ ១, លួចទ្រព្យគេ ១, ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ។

វចីទុច្ចរិត គឺអំពើដែលប្រព្រឹត្តអាក្រក់ដោយវាចា មាន ៤ យ៉ាងគឺៈ កុហក ១, និយាយញុះញង់គេ ១, និយាយពាក្យចាក់ដោត ១, និយាយពាក្យរោយរាយឥតប្រយោជន៍ ១ ។

មនោទុច្ចរិត គឺអំពើដែលប្រព្រឹត្តអាក្រក់ដោយចិត្ត មាន ៣ យ៉ាងគឺៈ លោភៈ ចង់បានរបស់គេ ១, ព្យាបាទៈ ប្រទូស្តគេ ១, មិច្ឆាទិដ្ឋិ ឃើញខុសចាកគន្លងធម៌ ១ ។

ទុច្ចរិតទាំង ៣ នេះ ជាកិច្ចមិនគួរធ្វើ គួរលះបេញ ។

ម៉្យាងទៀត ការសម្លាប់សត្វ លួចទ្រព្យគេ រហូតដល់ព្យាបាទប្រទូស្តគេ ធម៌ទាំងអស់នេះមិនបានអធិប្បាយឱ្យទូលំទូលាយទេ តែលោកអ្នកសិក្សាក៏អាចកាន់យកសេចក្តីអត្ថាធិប្បាយដោយពិស្តារបាន ។

ក្នុងទីនេះ សូមអធិប្បាយចំពោះតែការឃើញខុសចាកគន្លងធម៌ ឱ្យងាយចូលចិត្តដូចតទៅនេះ ៖ គតិក្នុងព្រះពុទ្ធ-សាសនាប្រកាន់ថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ សេចក្តីល្អនិងសេចក្តីអាក្រក់ ដែលបុគ្គលបានទទួលរាប់រង

សុទ្ធតែជាផលនៃកម្មល្អនិងកម្មអាក្រក់ ដែលខ្លួនបានធ្វើទុកពីខាងដើមទាំងអស់ ។

ម្យ៉ាងវិញទៀត បុគ្គលធ្វើសេចក្តីល្អ សូម្បីមិនទាន់បានទទួលផលល្អជាគ្រឿងប្រគល់ឱ្យ ក៏រមែងបានទទួលសេចក្តីរីករាយចិត្តរបស់ខ្លួនឯងមិនខាន បុគ្គលដែលធ្វើអំពើអាក្រក់រមែងបានទទួលសេចក្តីសៅហ្មងចិត្ត និងទុក្ខទោស មានប្រការផ្សេងៗ ត្រង់ការដែលពោលថា ឃើញខុសចាកគន្លងធម៌នោះ គឺឃើញថា ធ្វើការណានីមួយដែលចាត់ថាល្អ បើមិនមានមនុស្សដឹង មិនមានមនុស្សសរសើរ មិនមានមនុស្សឱ្យរង្វាន់ ក៏ទទេទាំងអស់ កាលណាមានមនុស្សដឹង មានមនុស្សសរសើរ និងមានមនុស្សឱ្យរង្វាន់ ទើបឱ្យគុណក្នុងកាលនោះ, ដែលចាត់ថាអាក្រក់នោះ បើមិនមានមនុស្សដឹង មិនមានមនុស្សចាប់បាន មិនមានមនុស្សដាក់ទោស ក៏ទទេទាំងអស់ដូចគ្នា កាលណាមានមនុស្សដឹង មានមនុស្សចាប់ មានមនុស្សដាក់ទោស ទើបឱ្យទោសទុក្ខក្នុងកាលនោះ ។

# សុចរិត ៣ យ៉ាង (10)

**១-កាយសុចរិត** ប្រព្រឹត្តល្អដោយកាយ;

**២-វចីសុចរិត** ប្រព្រឹត្តល្អដោយវាចា;

**៣-មនោសុចរិត** ប្រព្រឹត្តល្អដោយចិត្ត ។

អធិប្បាយថា:

កាយសុចរិត គឺអំពើដែលប្រព្រឹត្តល្អដោយកាយ មាន ៣ យ៉ាងគឺ: វៀរចាកសម្លាប់សត្វ ១, វៀរចាកលួចទ្រព្យគេ ១, វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ។

វចីសុចរិត គឺអំពើដែលប្រព្រឹត្តល្អដោយវាចា មាន ៤ យ៉ាងគឺ: វៀរចាកនិយាយពាក្យកុហក ១, វៀរចាកនិយាយពាក្យញុះញង់គេ ១, វៀរចាកនិយាយពាក្យចាក់ដោតគេ ១, វៀរចាកនិយាយពាក្យរោយរាយឥតប្រយោជន៍ ១ ។

មនោសុចរិត គឺអំពើដែលប្រព្រឹត្តល្អដោយចិត្ត មាន ៣ យ៉ាងគឺ: មិនលោភចង់បានរបស់គេ ១, មិនព្យាបាទប្រទូស្តគេ ១, យើញត្រូវតាមគន្លងធម៌ ១ ។

*សុចរិតទាំង ៣ នេះ ជាកិច្ចគួរធ្វើ គួរប្រព្រឹត្ត ។*

## អកុសលមូល ៣ យ៉ាង (11)

**១-លោភៈ** *ចង់បានមិនចេះចប់;*

**២-ទោសៈ** *គិតប្រទូស្តគេ;*

**៣-មោហៈ** *វង្វេងមិនដឹងការណ៍ពិត ។*

*កាលបើអកុសលមូល ៣ បនេះ ណាមួយមានហើយ អកុសលដទៃដែលមិនទាន់កើតរមែងកើតឡើង ដែលកើតឡើងហើយក៏ចំរើនច្រើនឡើង, ហេតុនេះ គួរលះឱ្យអស់ចេញ ។*

អធិប្បាយថា:

*លោភៈ ប្រែថា ចិត្តជាប់ជំពាក់ក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើម, ចែកជា ៨ យ៉ាងគឺ: ចិត្តប្រកបដោយសោមនស្ស ៤, ឧបេក្ខា ៤, ចិត្តដែលប្រកបដោយសោមនស្ស ៤ នោះ គឺ ចិត្តទី១ និងទី២ ប្រកបដោយទិដ្ឋិទាំងពីរគឺ សស្សតទិដ្ឋិនិង ឧច្ឆេទទិដ្ឋិ, សស្សតិទិដ្ឋិ យល់ឃើញថាសត្វកើតឡើងទៀង*

អ្នកណាធ្លាប់កើតជាជាតិជាអ្វី ដល់ទៅកើតជាតិមុខនៅដដែល, ឧច្ឆេទទិដ្ឋិ យល់ឃើញថាសត្វស្លាប់ហើយសូន្យលែងទៅកើតទៀត; បើបុគ្គលណាប្រកបដោយទិដ្ឋិទាំងពីរនេះណាមួយហើយ តែងធ្វើអំពើបាបឥតកោតញញើត ក្លៀវក្លាអង់អាចរីករាយ ព្រោះតែអំពើបាបទាំងនោះមិនឱ្យផល, ចិត្តទី១ កើតឡើងក្លៀវក្លាដោយទំនើងខ្លួនឯង, ចិត្តទី២ កើតឡើងដោយគេដឹកនាំ ឬបានស្តាប់អំពីសំណាក់បុគ្គលដទៃ, ចិត្តទី៣ និងទី៤ កើតឡើង ប្រកបដោយលោភៈដែរ តែប្រាសចាកទិដ្ឋិក៏គង់តែធ្វើអំពើបាបដែរ, ចិត្តទី៣ កើតឡើងដោយទំនើងខ្លួនឯងឥតមានគេដឹកនាំ, ចិត្តទី៤ កើតឡើងដោយគេដឹកនាំឬបានស្តាប់អំពីបុគ្គលដទៃ; ឧបេក្ខាចែកជា ៤ ចិត្តទី៥និងទី៦ ប្រកបដោយទិដ្ឋិដូចចិត្តទី១និងទី២, ចិត្តទី៧ និងទី ៨ ដូចចិត្តទី៣ និងទី ៤, ឧបេក្ខានិងសោមនស្ស ទាំងពីរនេះប្លែកគ្នាតែមួយធ្វើអំពើបាបដោយក្លៀវក្លារីករាយ ឧបេក្ខាធ្វើដោយកណ្តាលៗ មិនសូវក្លៀវក្លា ។

លោភៈនេះជាប់ជំពាក់ក្នុងអារម្មណ៍ ដូចស្វាជាប់ជ័រ, មានសេចក្ដីដំណាលថាៈ សត្វស្វាទៅស៊ីដំណាំអ្នកស្រុក ម្ចាស់គេយកជ័រទៅដាក់, សត្វស្វានោះជាសត្វឃើញជ័រស្មានថាជាវត្ថុដែលខ្លួនត្រូវការ ក៏លូកជើងស្ដាំជាប់ យកជើងឆ្វេងទៅដោះក៏ជាប់ទៀត, យកដៃទាំងពីរលូកដោះក៏ជាប់ទៀត, យកមាត់ទៅកកេរក៏ជាប់ទៀត, លុះម្ចាស់គេមកឃើញស្វាជាប់ក៏វាយសម្លាប់ទៅ មានឧបមាយ៉ាងណា, ចិត្តដែលជាប់ជំពាក់ក្នុងអារម្មណ៍ ក៏មានឧបមេយ្យដូច្នោះដែរ; សេចក្ដីលោភនេះបើបុគ្គលណាជាប់ជំពាក់ហើយ តែងឱ្យអន្តរាយវិនាសដល់ខ្លួនប្រាណថែមទៀត, សមដូចពុទ្ធភាសិតថា **លោភោ ធម្មានំ បរិបន្ថោ** សេចក្ដីលោភកើតឡើង ធ្វើឱ្យអន្តរាយដល់កុសលធម៌ទាំងឡាយ ឬឱ្យវិនាសដល់ខ្លួន, មានរឿងដំណាលថាៈ មានព្រានប្រមង់ម្នាក់ មានចិត្តលោភ, សម័យថ្ងៃមួយនោះទៅបង់សំណាញ់នៅស្ទឹងទន្លេ ក៏បង់ទៅជាប់គល់ឈើក៏នឹកស្មានថាជាប់ត្រីយ៉ាងធំ ព្រាននោះគិតថា បើអញបានត្រីនេះទៅ

ហើយ មុខជាអ្នកផ្ទះជិតខាងនឹងមកសុំអញមិនខាននាំឱ្យខាត លុះគិតដូច្នោះហើយ ក៏ប្រើកូនដែលទៅជាមួយនឹងខ្លួនឱ្យទៅប្រាប់ម្ដាយឱ្យដើរឈ្មោះអ្នកជិតខាងឱ្យអស់, កូនក៏ទៅប្រាប់ម្ដាយថា ឪពុកឱ្យអ្នកម្ដាយដើរឈ្មោះគេឱ្យអស់ទៅ ព្រោះគាត់បង់បានត្រីធំណាស់ ម្ដាយនោះស្ដាប់ហើយក៏គិតថា អាត្មាអញរកឧបាយកលដូចម្ដេចហ្ន៎! បើដូច្នេះមានតែអញយកសំពត់កញ្ចាស់មករុំស្នៀកវណ្ណ ហើយបីកូនក្ដៅដើរកាត់ភូមិ អ្នកស្រុកឃើញហើយក៏អស់សំណើចគ្រប់គ្នា, នាងនោះក៏ដេរបញ្ចោពាក្យទៅលើមាខ្លះមីងខ្លះ អ្នកដទៃខ្លះ កូននោះក៏ត្រឡប់ទៅប្រាប់ឪពុកវិញ ថាម្ដាយបានដើរឈ្មោះគេអស់ហើយ, ព្រាននោះក៏ឱ្យកូនទាញសំណាញ់ គាត់ក៏មុជទៅក្នុងទឹកដើម្បីចាប់ត្រីដែលជាប់សំណាញ់នោះ, លុះមុជទៅ ក៏ស្រាប់តែជល់នឹងគល់ឈើបែកភ្នែកខ្វាក់ទាំងពីរទៅ, សំពត់ដែលនៅលើមាត់ច្រាំងនោះ ស្រាប់តែខ្យល់កំបុតត្បូងក្ដួចឡើងទៅបាត់, ចំណែកភរិយាដែលខំដើរឈ្មោះប្រកែកចំ

ទៅលើមាមីផនោះ គេក៏ប្តឹផផ្តល់ខូចខាតទ្រព្យសម្បត្តិអស់ ទ្រព្យនៅវាលក៏វិនាស ឯផ្ទះក៏វិនាស, នេះព្រោះតែសេចក្តីលោភ ។

ទោសប្រទូសរ៉ាយគេនោះ មិនថាអ្នកណាៗ ទេ ឱ្យតែទាស់ចិត្ត ក៏ចេះតែប្រទូស្តទាំផអស់ ដូចជាភ្លើផឆេះព្រៃ ឆេះទីឯផអស់ហើយក៏រាលដាលទៅឆេះព្រៃដទៃទៀត យ៉ាផណា, ទោសៈ បើកើតក្នុផខន្ធសន្តានបុគ្គលណាហើយ បុគ្គលនោះរមែផប្រទូស្តកូនប្រពន្ធរបស់ខ្លួនអស់ហើយ ក៏ប្រទូស្តអ្នកដទៃទៀត, ទោសៈប្រទូសរ៉ាយនេះ បើស្លាប់ពីនេះទៅរមែផទៅកើតក្នុផនរក សេសសល់ផលកម្ម មកកើតជាប្រេតដូចអជគរប្រេត; មានរឿផដំណាលថាៈ

កស្សបពុទ្ធកាលេ កិរ សុមង្គលេសេដ្ឋី នាម សុវណ្ណិដ្ឋិកាហិ ភូមិយំ បត្ថរិត្វា វីសតិឧសភដ្ឋានេ តត្តកោនេវ ធនេន វិហារំ ការេត្វា តាវតកោនេវ វិហារមហំ ការេសិ ។បេ។ ចោរោ តំ កម្មំ កត្វា អាយុបរិយោសានេ អវីចិម្ហិ និព្វត្តោ

**ជីឃរត្តំ បចិត្វា វិចាភោវសេឌ ឥជាឆិ កិជ្ឈកូដបញ្ចូតេ អជតរបេតោ ហុត្វា បច្ចតីតិ ។**

បានឮមកថា: ក្នុងពុទ្ធកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ មានសេដ្ឋីម្នាក់ឈ្មោះសុមនៈ បានក្រាលឥដ្ឋមាសលើផែនដី ក្នុងទីទំហំ ២០ ឧសភៈហើយឱ្យជាងសាងវិហារដោយទ្រព្យប៉ុណ្ណោះ, លុះធ្វើរួចហើយ ក៏ធ្វើបុណ្យឆ្លងវិហារដោយទ្រព្យប៉ុណ្ណោះទៀត ។ ថ្ងៃមួយ សេដ្ឋីនោះទៅកាន់សំណាក់ព្រះសាស្ដាពីព្រលឹម, បានឃើញចោរប្រឡាក់ភក់ជើងដេកទទូរក្បាលនៅលើសាលាទៀបទ្វារនគរ ក៏និយាយថា បុរសនេះប្រឡាក់ភក់ជើង ប្រហែលជាមនុស្សដើរយប់ហើយ ទើបមកដេកទេដឹង? ចោរបើកមុខមើលឃើញសេដ្ឋីក៏ចងគំនុំថា «គង់តែនឹងដឹងគ្នាទេ», ហើយក៏ព្យាយាមដុតស្រែសេដ្ឋីនោះអស់ ៧ ដង, កាត់ជើងគោក្នុងក្រោលអស់ ៧ ដង, ដុតផ្ទះអស់ ៧ ដង; ប៉ុណ្ណោះហើយក៏នៅតែមិនទាន់បាត់ខឹង, ទើបវាអែបធ្វើជាមិត្តសម្លាញ់នឹងចូឡុបដ្ឋាក (កូនក្មួយ) របស់សេដ្ឋីនោះម្នាក់ ហើយសួរថា សេដ្ឋីស្រឡាញ់អ្វីជាងគេ, បុរសនោះប្រាប់ថា

គាត់គ្មានអ្វីស្រឡាញ់ជាងគន្ធកុដិទេ ។ ទើបវាគិតថា ‹‹អញនឹងដុតគន្ធកុដិ ទើបរម្ងាប់សេចក្ដីក្រោធបាន››; កាលបើព្រះសាស្ដាទ្រង់ចូលទៅបិណ្ឌបាតបាត់ វាក៏វាយបំបែកពាងសំរាប់ដាក់ទឹកឆាន់ទឹកប្រើប្រាស់ ហើយដុតគន្ធកុដិទៀត ។ សេដ្ឋីឮថា ភ្លើងឆេះគន្ធកុដិក៏មកមើល, ហើយគ្មានទោមនស្សសូម្បីប៉ុនរោមទ្រាយឡើយ, បែរជាទះដៃទៅវិញ, ដោយគិតថា ‹‹អញមុខជានឹងបានចំណាយទ្រព្យប៉ុណ្ណោះធ្វើគន្ធកុដិថ្វាយព្រះសាស្ដាម្ដងទៀត›› ហើយក៏ចាត់ចែងធ្វើជាថ្មីឡើង ។ ឯចោរបានឃើញដូច្នោះហើយ ក៏គិតថា ‹‹បើអញមិនសម្លាប់សេដ្ឋីនេះ, មិនបាត់អៀនខ្មាស់ទេ››, ទើបសៀតកាំបិតស្នៀតក្នុងសំពត់ដើរទៅក្នុងវត្តអស់ ៧ ថ្ងៃ, តែមិនបានឱកាសនឹងសម្លាប់សោះ ។ ចំណែកខាងមហាសេដ្ឋី ថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយថ្វាយបង្គំព្រះសាស្ដា ក្រាបទូលថាបពិត្រព្រះអង្គដ៏ចំរើន, ពីថ្ងៃមុនមានបុរសម្នាក់ដុតស្រែខ្ញុំអស់ ៧ ដង, កាត់ជើងគោក្នុងក្រោលអស់

៧ ដង, ដុតផ្ទះអស់ ៧ ដង; ឥឡូវនេះគន្ធកុដិប្រហែលជាបុរសនោះដុតដែរដឹង? បើដូច្នោះ, ខ្ញុំព្រះអង្គសូមឱ្យចំណែកបុណ្យជាដំបូងក្នុងទាននេះដល់បុរសនោះ ។ ចោរឮដូច្នោះហើយ ក៏គិតថា ‹‹យីអើ! កម្មដែលអញធ្វើហើយធ្ងន់ណាស់តើ! សេដ្ឋីគ្មានសេចក្ដីក្រោធនឹងអញសោះ, បែរជាឱ្យចំណែកបុណ្យមកអញវិញ; ដូច្នេះគួរតែអញអង្វរករគាត់ឱ្យគាត់អត់ទោសឱ្យចុះ; បើអញមិនឱ្យបុរសបែបនេះអត់ទោសឱ្យទេ, មុខជាអាជ្ញាទេពតានឹងធ្លាក់លើក្បាលអញមិនខាន››, ហើយក៏ចូលទៅក្រាបក្នុងទីជិតជើងសេដ្ឋី និយាយប្រាប់រឿងរ៉ាវសព្វគ្រប់ប្រការហើយសូមឱ្យសេដ្ឋីអត់ទោសឱ្យ ។ សេដ្ឋីក៏នឹកឃើញពាក្យដែលខ្លួននិយាយ ពីកាលដែលឃើញបុរសចោរនោះដេកលើសាលា ហើយក៏ឱ្យចោរនោះអត់ទោសឱ្យដោយពាក្យថា អើអ្នក! ខ្ញុំបាននិយាយដូច្នេះៗ, នោះចូរអ្នកអត់ទោសឱ្យខ្ញុំផងចុះ, ចូរអ្នកក្រោកឡើង, ខ្ញុំអត់ទោសឱ្យអ្នកវិញហើយ, ចូរអ្នកទៅចុះ ។ ចោរនិយាយថា លោកម្ចាស់, បើ

លោកអត់ទោសដល់ខ្ញុំហើយ សូមលោកធ្វើខ្ញុំព្រមទាំងកូននិងប្រពន្ធឱ្យជាខ្ញុំកំដរនៅក្នុងផ្ទះលោកផង ។ សេដ្ឋីថា នែអ្នកខ្ញុំគ្រាន់តែថាប៉ុណ្ណោះ អ្នកឯងហ៊ានធ្វើយ៉ាងនេះទៅហើយ, ចំណង់បើអ្នកឯងទៅនៅជាមួយនឹងខ្ញុំ ស្តីថាដូចម្តេចបាន, ខ្ញុំមិនឱ្យអ្នកឯងនៅទេ, ខ្ញុំគ្រាន់តែអត់ទោសឱ្យអ្នកឯងប៉ុណ្ណោះ, ចូរអ្នកឯងទៅចុះ ។

ចោរបានធ្វើកម្មប៉ុណ្ណោះ លុះអស់អាយុ ក៏ទៅកើតក្នុងនរកអវីចិ ឆេះនៅក្នុងនរកនោះអស់កាលជាយូរអង្វែង ដោយសេសសល់ផលកម្មនោះ ក៏បានមកកើតជាអជគរប្រេត ឆេះនៅលើភ្នំគិជ្ឈកូដឥឡូវនេះឯង ។

មោហៈ រង្វេងក័ន្តច្រឡំដូចជាសត្វមមាចឃើញពន្លឺភ្លើង ក៏នឹកស្មានថាជារបស់ល្អ ក៏ហើរចូលទៅក្នុងភ្លើងនោះ, ភ្លើងក៏ឆេះស្លាប់អស់ទៅយ៉ាងណា, បុគ្គលដែលប្រកបដោយមោហៈក៏យ៉ាងនោះដែរ ។

ការសម្លាប់សត្វ លួចទ្រព្យគេជាដើម ក៏សុទ្ធតែមាន លោភៈ ទោសៈ មោហៈជាមូល ។

អកុសលមូលទាំង ៣ ប្រការនេះ ជាឫសគល់ ជាហេតុ ជាទីតាំងនៃការធ្វើសេចក្តីអាក្រក់ដទៃៗ ឧទាហរណ៍ដូចជា មនុស្សមានសេចក្តីលោភចង់បានមិនរើសវេលា មិនកំណត់ ចំនួន មិនពិចារណាឱ្យឃើញថាគួរឬមិនគួរ កាលសេចក្តីចង់ បានចាស់ក្លា រមែងបិទបាំងមិនឱ្យឃើញបាបបុណ្យ គុណ ទោស អាក្រក់ ល្អ ស ខ្មៅ ប្រយោជន៍ និងមិនមែនប្រយោជន៍ ឡើយ ។ កាលបើសេចក្តីចង់បានមិនសមតាមវត្ថុបំណងរបស់ ខ្លួន អាស្រ័យដោយមានឧបសគ្គឧបទ្រវន្តរាយទាំងឡាយមក ស្ទាក់រាំងរាដំណើរ រមែងឱ្យកើតទោសៈគិតប្រទូស្តគេ ប្រាស- ចាកមេត្តាករុណាដល់សត្វទាំងឡាយ ។ ឯមោហៈ សេចក្តី វង្វេង, សេចក្តីល្ងង់ខ្លៅ, សេចក្តីចូលចិត្តខុស, គិតមិនទាន់, ដឹងមិនដល់ហេតុការណ៍ទាំងប៉ុន្មាននេះ ជាលក្ខណៈរបស់ មោហៈៗ រមែងគ្របដណ្តប់ឃុំឃាំងទូទៅ ដល់លោភៈនិង

ទោសៈ ព្រោះសេចក្តីមិនដឹងដល់ការណ៍ ទើបបណ្តាលឱ្យកើតលោភ និងគិតប្រទូស្តដល់អ្នកដទៃ ។

ធម៌ទាំង ៣ ប្រការនេះ ជាឫសគល់អកុសលដូចបានពណ៌នាមកដោយសេចក្តីសង្ខេបនេះ ។

កាលបើបុគ្គលឃើញទោសទាំងអម្បាលនេះហើយ គប្បីកំចាត់បង់នូវលោភៈដោយការឱ្យទាន, កំចាត់ទោសៈដោយការរក្សាសីល, កំចាត់មោហៈដោយការចំរើនភាវនា ។

## កុសលមូល ៣ យ៉ាង (12)

១-អលោភៈ មិនចង់បាន;

២-អទោសៈ មិនគិតប្រទូស្ត;

៣-អមោហៈ មិនវង្វេង ។

កាលបើកុសលមូលទាំង ៣ នេះ ណាមួយមានហើយ កុសលដទៃដែលមិនទាន់កើត រមែងកើតឡើង ដែលកើត

ឡើងហើយក៏ចម្រើនច្រើនឡើង, ហេតុនេះគួរធ្វើឱ្យកើតមានក្នុងសន្តាន ។

អធិប្បាយថា:

មនុស្សដែលមានចិត្តទូលំទូលាយ រមែងចែករបស់ខ្លួនឱ្យដល់អ្នកដទៃតាមសមគួរ ឬក៏ជាអ្នកមានសន្តោស ត្រេកអរចំពោះបច្ច័យតាមមានតាមបាន ឈ្មោះថាជាអ្នកមិនមានសេចក្តីលោភ ។ អ្នកដែលមានមេត្តាចិត្ត គិតអាណិតអាសូរមិនបៀតបៀនអ្នកដទៃ ឱ្យបានសេចក្តីក្តៅក្រហាយ ឈ្មោះថាជាអ្នកមិនមានទោសៈ ។ ភាពជាអ្នកមិនវង្វេងភ្លាំងភ្លេចស្មារតីដឹងហេតុការណ៍អ្វីទាន់តាមធម្មតា រហូតដល់ដឹងធម៌ជាន់ខ្ពស់គឺអរិយសច្ច ៤ ប្រការ ឈ្មោះថាជាអ្នកមិនវង្វេង ដែលពោលមកនេះជាបុគ្គលាធិដ្ឋាន ។

ចំណែកធម្មាធិដ្ឋាន គប្បីជ្រាបដោយសំដែងលើកធម៌ឡើងជាទីតាំង, បរិយាយរបស់លក្ខណធម៌ ដូចជាសេចក្តីមិន

លោកមានលក្ខណៈត្រេកអរចំពោះវត្ថុជារបស់ខ្លួន ដូច្នេះជាដើម ។

គុណគឺសេចក្ដីល្អដទៃៗ ដែលនឹងកើតឡើង ក៏អាស្រ័យដោយធម៌ទាំង ៣ ប្រការនេះជាឫសគល់ជាដើមចម ហេតុនេះគួរណាស់តែអ្នកប្រតិបត្តិធម៌ គប្បីអប់រំឱ្យកើងមានឡើងក្នុងខន្ធសន្ដានកុំខាន ។

**សប្បុរិសបញ្ញត្តិ** ‹‹បញ្ញត្តិរបស់សប្បុរស›› **៣ យ៉ាង** (13)

**១-ទានៈ** ឱ្យវត្ថុរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់អ្នកដទៃ;

**២-បព្វជ្ជា** កានភេទបួសដើម្បីជាឧបាយវៀរចាកធម៌សម្រាប់គ្រប់គ្រងផ្ទះ;

**៣-មាតាបិតុបដ្ឋាន** ប្រតិបត្តិមាតាបិតាតាមគន្លងធម៌ ។

**អធិប្បាយថាៈ**

សប្បុរសគឺមនុស្សល្អ មានសន្ដានចិត្តស្ងប់រម្ងាប់ចាកបាបជាអកុសល ពិចារណាឃើញធម៌ ៣ ប្រការនេះ ប្រព្រឹត្តទៅក្នុងផ្លូវដែលត្រូវ, គួរសាធុជនប្រកបឱ្យកើតមានឡើង, ដើម្បី

សេចក្តីសុខ សេចក្តីចម្រើនដល់ខ្លួនក្នុងលោកនេះនិងលោកខាងមុខ ទើបព្រះអង្គទ្រង់បញ្ញត្តទុក, មួយទៀត ទុកជាការចងមេត្រីចិត្ត, ជាសង្គហវត្ថុជាគ្រឿងតោងទាញទឹកចិត្តរវាងគ្នានិងគ្នា, ប្រព្រឹត្តទៅក្នុងផ្លូវមេត្តា ករុណា អនុគ្រោះដល់គ្នានិងគ្នា ។ទានៈ ដែលលោកអ្នកមានសន្តានចិត្តដ៏ល្អ អាចចែករំលែកដល់បុគ្គលដែលមានសន្តានចិត្តដ៏ល្អនោះ, អ្នកសិក្សាគប្បីមើលក្នុងទានមយៈនៃបុញ្ញកិរិយាវត្ថុឯណោះ ទើបមានសេចក្តីអធិប្បាយទូលំទូលាយជាងនេះ ។

ម្យ៉ាងទៀត ជាឧបាយវៀរចាកអាឃាតព្យាបាទបៀតបៀនគ្នា ព្រោះអ្នកដែលកាន់ភេទបួស ត្រូវតាមធម្មវិន័យជាគ្រឿងប្រព្រឹត្ត ។

ម្យ៉ាងវិញទៀត ប្រតិបត្តិមាតាបិតារបស់ខ្លួនឱ្យជាសុខគុណបែបនេះ បុគ្គលណាបំពេញឱ្យមានជានិច្ចតាមឋានៈរបស់ខ្លួន បុគ្គលនោះឈ្មោះថា អ្នកកតញ្ញូកតវេទី ជាមនុស្សល្អក្នុងព្រះពុទ្ធសាសនា, ព្រោះមានភាសិតសំដែងថា «**និមិត្តិ**

**សាធុរូបានិ កតញ្ញូ កតវេទិតា** *ភាពជាមនុស្ស កតញ្ញូកតវេទី ជាគ្រឿងសម្គាល់របស់មនុស្សល្អ» ។*

## អាបណ្ណកប្បដិបទា ៣ យ៉ាង (14)

**១-ឥន្ទ្រិយសំវរៈ** *សង្រួមឥន្ទ្រិយ ៦ គឺភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត មិនឱ្យមានសោមនស្ស ទោមនស្សក្នុងវេលាដែលឃើញរូប, ឮសម្លេង, ធុំក្លិន, ស្រូបរស, កាយពាល់ត្រូវ, ដឹងធម្មារម្មណ៍ដោយចិត្ត ។*

**២-ភោជនេ មត្តញ្ញុតា** *ស្គាល់ប្រមាណក្នុងការបរិភោគអាហារតែល្មមសមគួរ មិនច្រើនមិនតិច;*

**៣-ជាគរិយានុយោគះ** *ប្រកបសេចក្តីព្យាយាមដើម្បីជម្រះចិត្តឱ្យបរិសុទ្ធហ្មត់ចត់ មិនឃើញដល់ការដេកច្រើន ។*

*អធិប្បាយថា:*

*ធម៌ទាំងបីប្រការនេះ មានឈ្មោះថាការបដិបត្តិមិនខុស អាចនាំអ្នកប្រតិបត្តិឱ្យសម្រេចផល គឺសេចក្តីសុខ និង*

ប្រយោជន៍ដទៃៗ ត្រូវតាមការ គួយ៉ាងដូចជាបុគ្គលសង្រួមឥន្ទ្រិយទាំង ៦ មិនឱ្យកើតសោមនស្សទោមនស្សចំពោះអារម្មណ៍នោះៗ រមែងឱ្យកើតសេចក្តីសុខ មិនសោកសៅតូចចិត្តក្នុងកាលជួបប្រទះអារម្មណ៍ ដែលមិនជាទីពេញចិត្ត ឬអារម្មណ៍ដែលជាទីពេញចិត្តហើយវិបត្តិទៅ, ដោយអាការៈណានីមួយ ។

ការដឹងប្រមាណក្នុងអាហារ ក៏រាប់ថាជាគុណប្រយោជន៍យ៉ាងសំខាន់ ព្រោះអ្នកប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា ឬក៏ប្រកបការងារក្នុងផ្លូវលោកក៏ដោយ, ការដឹងប្រមាណក្នុងអាហារទើបប្រកបការងារនោះៗ ទៅបានពេញទី, ព្រោះថាបើបរិភោគហួសប្រមាណ ក៏នឹងធ្វើឱ្យបត់ប្រមល់ចង្អៀតចង្អល់ខ្ជិលច្រអូស, បើបរិភោគតិចពេក ក៏ធ្វើឱ្យល្វឹងល្វើយស្រេកឃ្លាន ចិត្តក៏រវើរវាយ, ការដឹងប្រមាណក្នុងអាហារដ៏ល្មមល្អ ទើបមានប្រយោជន៍ ដូចបានពោលមកហើយ ។

អ្នកដែលបំពេញសេចក្ដីព្យាយាម មិនគួរដេកច្រើនទេ, ព្រោះការដេកច្រើនជាសត្រូវដល់សេចក្ដីព្យាយាម, លោកពោលថា គួរឱ្យមានសតិភ្ញាក់រឭកជានិច្ច, ដូចសេះដែលនាយសារថីវាយដោយរំពាត់ដូច្នោះ, កាលបើមិនឃើញដល់ការដេកច្រើនហើយ ក៏តាំងចិត្តប្រកបដោយសេចក្ដីព្យាយាម អាចជំរះចិត្តឱ្យផូរផង់ចាកកិលេសជាគ្រឿងសៅហ្មង តាមសេចក្ដីប្រាថ្នារបស់ខ្លួនបាន ។

## បុញ្ញកិរិយាវត្ថុ ៣ យ៉ាង (15)

‹‹វត្ថុជាទីតាំងនៃការបំពេញបុណ្យ››

**១-ទានមយៈ** បុណ្យសម្រេចដោយការបរិច្ចាគទាន;

**២-សីលមយៈ** បុណ្យសម្រេចដោយការរក្សាសីល;

**៣-ភាវនាមយៈ** បុណ្យសម្រេចដោយការចំរើនភាវនា ។

**អធិប្បាយថា:**

ទានៈ ប្រែថា ‹‹វត្ថុដែលគេគប្បីឱ្យ›› មាន ២ យ៉ាងគឺ: អាមិសទាន ១, ធម្មទាន ១ ។ អាមិសទាន បានដល់ចេតនាជា

គ្រឿងលះបង់នូវអាមិសវត្ថុ គឺបច្ច័យទាំង ៤ ៖ ចីវរប្បច្ច័យ ១, បិណ្ឌបាតប្បច្ច័យ ១, សេនាសនប្បច្ច័យ ១, គិលានភេសជ្ជ-ប្បច្ច័យ ១ ។ បុគ្គលដែលប្រកបដោយសទ្ធា បានធ្វើចេតនាដោយបច្ច័យទាំង ៤ នោះ រមែងបាននូវអានិសង្សផ្សេងៗ និងប្រយោជន៍ សេចក្ដីសុខចម្រើន, ដូចមាននិទានដំណាលថា:

**អតីតេ ពារាណសិវាសី ឯកោ កុដុម្ពិកោ** កាលកន្លងទៅហើយមានកុដុម្ពីក៏ម្នាក់ នៅក្នុងនគរពារាណសី, មានកាលមួយថ្ងៃ បានត្រាច់ដើរទៅក្នុងព្រៃ បានជួបនឹងព្រះបច្ចេកពុទ្ធមួយអង្គកំពុងដេរចីពរ នៅខ្វះសំពត់មិនទាន់គ្រប់គ្រាន់ត្រង់អនុវាទបណ្ដោយ ។ ឯកុដុម្ពិកនោះ ក៏មានចិត្តជ្រះថ្លាហើយយកសំពត់សម្រាប់បង់ករបស់ខ្លួន ប្រគេនទៅព្រះបច្ចេកពុទ្ធដោយអានុភាពនៃបុញ្ញកម្មនោះ បុរសនោះអស់អាយុសង្ខារទៅ បានទៅកើតក្នុងឋានតាវតិង្សទេវលោក បានសោយទិព្វ-សម្បត្តិជាយូរអង្វែង លុះច្យុតអំពីទេវលោកនោះមក ក៏បានមកកើតក្នុងត្រកូលអាមាត្យនៅក្នុងទីចម្ងាយ ១ យោជន៍អំពី

នគរពារាណសី, បុរសនោះលុះមានវ័យវឌ្ឍនាការចំរើនធំឡើង មានកាលថ្ងៃមួយ ជាថ្ងៃលេងនក្ខត្តឫក្ស បុរសនោះនិយាយនឹងមាតារបស់ខ្លួនថា បពិត្រលោកម្តាយ ចូរឱ្យសំពត់មួយមកខ្ញុំៗ នឹងទៅលេងនក្ខត្តឫក្សនឹងគេ មាតានោះក៏ឱ្យសំពត់ស្អាតមួយទៅ បុរសនោះនិយាយថា សំពត់នេះមានសាច់គ្រោតគ្រាតណាស់ខ្ញុំមិនយកទេ ។ មាតាក៏ឱ្យសំពត់ដទៃទៀត បុរសនោះក៏មិនព្រមយកសំពត់នោះទៀត ។ មាតានិយាយថា ក្នុងផ្ទះយើងមិនមានសំពត់ឯណាល្អជាងសំពត់នេះទៀតទេ ។ បុរសនោះនិយាយថា បើដូច្នេះខ្ញុំទៅស្វែងរកសំពត់គួរជាទីគាប់ចិត្តឱ្យបាន ។ មាតានិយាយថា ម្នាលកូន! ម្តាយមិនស្អប់កូនទេ សព្វថ្ងៃនេះ ម្តាយមានចិត្តចង់ឱ្យកូនឯងសោយរាជ្យក្នុងនគរពារាណសីនេះផង ។ បុរសនោះក៏ថ្វាយបង្គំមាតាដើរចេញទៅ ហេតុតែមានកុសលរាសីអំពីបុព្វជាតិក៏ត្រូវមានកំណាប់បុណ្យមកដាស់តឿន បុរសនោះដើរចូលទៅកាន់នគរពារាណសី ទៅដេកទទូរលើផែនថ្មមង្គលសិលា

ក្នុងសួនឧទ្យាន ។ កាលនោះ ជាថ្ងៃព្រះរាជាក្នុងនគរពារាណសីទ្រង់សោយទីវង្គតទៅបាន ៧ ថ្ងៃហើយ ។ ពួកជនមានអាមាត្យជាដើម នាំគ្នាធ្វើសរីរកិច្ចដល់ព្រះរាជាជាស្រេច ក៏ប្រឹក្សាគ្នាថា ឥឡូវនេះ ព្រះរាជាមានតែព្រះរាជធីតា ១, ឯព្រះរាជបុត្រមិនមានឡើយ; ធម្មតាស្រុកនគរបើឥតមានស្តេចនឹងមិនបានឋិតថេរនៅឡើយ គឺថានឹងវិនាសទៅជាប្រាកដ, ហើយក៏រៀបចំបុស្សរថ ទឹមសេះសិន្ធព ៤ មានសម្បុរដូចផ្កាកុមុទ ហើយយករាជកកុដភណ្ឌ ([1]) ទាំង ៥ ប្រការ តម្កល់លើរថ ហើយក៏លែងបុស្សរថទៅ ។ ចំណែកបុស្សរថក៏ចេញទៅតាមទ្វារខាងកើត ចូលទៅកាន់សួនឧទ្យាន ហើយប្រទក្សិណកុមារដែលដេកក្នុងទីនោះ ហើយឈប់នៅស្ងៀម បម្រុងប្រុងប្រៀបនឹងឱ្យកុមារឡើងជិះ ។

ចំណែកបុរោហិត ក៏បើកជាយសំពត់ដណ្តប់ឡើង ហើយរមិលមើលផ្ទៃជើងសព្វគ្រប់ហើយទាយថា បុរសនេះសមគួរ

[1] -គ្រឿងប្រដាប់សម្រាប់អភិសេកស្តេច គឺ ខគ្គោ ព្រះខ័ន ១, ឆត្តំ ឆ័ត្រ ១, ឧណ្ហិលំ មកុដ ឬក្បាំង ១, បាទុកា ទ្រនាប់ជើង (ឆ្លងព្រះបាទា) ១, វាលវិជនី ផ្លិតរោមកន្ទុយសត្វ ១ ។

នឹងសោយរាជ្យបាន ហើយប្រគំតូរ្យតន្ត្រីអស់រារៈបីដង ។ លំដាប់នោះ កុមារបើកមុខឡើងសួរថា អ្នកទាំងឡាយនាំគ្នាមករកអ្វី? ជនទាំងឡាយតបថា បពិត្រព្រះសម្មតិទេព ឥឡូវរាជសម្បត្តិធ្លាក់លើព្រះអង្គហើយ ។ កុមារសួរថា ចុះព្រះរាជារបស់អ្នកទាំងឡាយទៅឯណា? ព្រះរាជារបស់យើងខ្ញុំទាំង-ឡាយព្រះអង្គសោយទិវង្គតហើយ ។ -សោយព្រះទិវង្គតទៅប៉ុន្មានថ្ងៃហើយ? -មកដល់ថ្ងៃនេះ ៧ ថ្ងៃហើយ; -ចុះព្រះរាជ-បុត្រក្តី ព្រះរាជធីតាក្តី មិនមានទេឬ? -មានតែព្រះរាជធីតា, ព្រះរាជបុត្រពុំមានទេ ។ កុមារឆ្លើយថា បើដូច្នោះ យើងនឹងសោយរាជ្យចុះ ។ ជនទាំងនោះ ក៏ធ្វើមណ្ឌបសម្រាប់អភិសេកមួយរំពេច ហើយក៏រៀបចំអភិសេកក្នុងមណ្ឌបនោះ ថ្វាយព្រះនាមថា «ព្រះបាទនន្ទរាជ» ហើយនាំយកសំពត់មានតម្លៃ ១ ពាន់កហាបណៈទៅថ្វាយ ។ ព្រះរាជានោះមានព្រះបន្ទូលថា សំពត់នេះជាសំពត់មានសាច់គគ្រាតពេកណាស់ យើងមិនត្រូវការទេ, អ្នកទាំងឡាយចូរយកកុណ្ឌីមាសមក យើងមុខជា

នឹងបានសំពត់ល្អ ហើយក៏ក្រោកឡើង យកព្រះហស្តកាន់ទឹកបាចសាចទៅក្នុងទិសខាងកើត ។ ដើមកល្បព្រឹក្ស ៨ ដើម ក៏ទម្លាយផែនដីផុះឡើងភ្លាម ។ ទិសខាងត្បូងក្តី ខាងលិចក្តី ខាងជើងក្តី មានដើមកល្បព្រឹក្ស ៨ ដើមៗ ផុសឡើងដូចគ្នា ។ សំពត់ក៏កើតឡើងបរិបូណ៌ ក្នុងដើមកល្បព្រឹក្សអម្បាលនោះ ។ ព្រះរាជានោះ ក៏ទ្រង់ស្លៀកសំពត់ទិព្វ ១ ដណ្តប់សំពត់ទិព្វ ១ ហើយទ្រង់ឱ្យទូងគេរីប្រកាសប្រាប់មនុស្សទាំង-អស់នៅក្នុងដែនថា ពួកស្ត្រីក្នុងដែនព្រះបាទនន្ទរាជ កុំចាំបាច់រវៃសូត្រអម្បោះឡើយ, ហើយទ្រង់ឱ្យលើកឆ័ត្រឡើង ទ្រង់គង់លើដំរីដ៏ប្រសើរ យាងចូលទៅកាន់ព្រះនគរ ទ្រង់ឡើងកាន់ប្រាសាទសោយសម្បត្តិដ៏ថ្កុំថ្កើង ទ្រង់រៀបចំដែនទាំងមូលឱ្យល្អស្អាត ប្រហែលនឹងឧត្តរកុរុទ្វីប, ទ្រង់ព្រះរាជទានសំពត់ទិព្វដល់មនុស្សដែលមកទាំងអម្បាលម៉ាន, លុះកាលជាចំណេរខាងក្រោយមក ទ្រង់មានសេចក្តីនឿយណាយក្នុងឃរាវាស ហើយទ្រង់ព្រះផ្នួសជាមួយនឹងនាងទេវីជាអគ្គមហេសី ទ្រង់

គង់នៅក្នុងឧទ្យាន ក៏បានឈានសមាបត្តិមានភាពជាបុគ្គល មិនបានសាបសូន្យចាកឈាន លុះអស់ព្រះជន្មាយុទៅ ក៏បានទៅកើតក្នុងព្រហ្មលោកនាយ ។

ព្រះបាទនន្ទរាជនោះ គឺព្រះមហាកស្សបត្ថេរ ក្នុងកាលឥឡូវនេះ, ឯនាងទេវីគឺនាងភទ្ទាកាបិលានី ជាភរិយាព្រះថេរៈក្នុងកាលនៅជាគ្រហស្ថ ។

សំដែងរឿងនេះ ដើម្បីញុាំងសាធុជនឱ្យជ្រាបក្នុងអានិសង្សចីវរទាន ដែលបុគ្គលបានធ្វើដល់ព្រះអរិយបុគ្គល ជាបុញ្ញក្ខេត្តដ៏វិសេស ។

មានរឿងមួយទៀតដំណាលថា: ក្នុងនគរសាវត្ថី មានធីតានៃនាយមាលាការម្នាក់ ជាស្ត្រីមានរូបល្អមានបញ្ញាច្រើន អាយុ ១៦ ឆ្នាំ ។ មានកាលថ្ងៃមួយ នាងធីតានោះយកនំ ៣ ដុំដាក់ក្នុងប្រែងដែលសម្រាប់ដាក់ផ្កា ដើរទៅកាន់ច្បារផ្កា នាងក៏បានឃើញព្រះសាស្តា ព្រមទាំងព្រះភិក្ខុសង្ឃ កំពុងនិមន្តទៅកាន់នគរដើម្បីបិណ្ឌបាត នាងក៏មានចិត្តត្រេកអរ យកនំ

ទៅដាក់ក្នុងបាត្រព្រះសាស្តា រួចហើយថ្វាយបង្គំញ៉ាំងបីតិមានព្រះពុទ្ធជាអារម្មណ៍ឱ្យកើតឡើង ហើយឈរនៅក្នុងទីដ៏សមគួរ ។ ព្រះសាស្តាទ្រង់រមិលមើលនាងជីតានោះ ទ្រង់ធ្វើព្រះកេ្រញញឹម ព្រះអានន្ទត្ថេរក្រាបបង្គំទូលសួរអំពីហេតុដែលទ្រង់ញញឹម ព្រះអង្គមានព្រះបន្ទូលថា ម្នាលអានន្ទ! , នាងកុមារិកានេះ នឹងបានជាអគ្គមហេសីនៃព្រះបាទកោសលរាជក្នុងថ្ងៃនេះឯង ដោយអំណាចផលទាននំនេះមិនខានឡើយ ហើយទ្រង់យាងជៀសចេញទៅ ។ ឯនាងជីតានោះ ក៏ដើរចូលទៅកាន់ច្បារផ្កា ស្រែកច្រៀងបណ្តើរ បេះផ្កាបណ្តើរ ។ ជួនជាក្នុងពេលនោះឯង ព្រះបាទកោសលរាជទ្រង់ច្បាំងនឹងព្រះបាទជាតសត្តុ ចាញ់ទ័ពព្រះបាទអជាតសត្តុក៏រត់ចេញមក ទ្រង់គង់លើព្រះទីនាំងសេះបរមកបានឮសម្លេងនាងជីតានោះច្រៀង ក៏មានព្រះទ័យប្រតិព័ទ្ធ ទ្រង់យាងចូលទៅច្បារផ្កា ទ្រង់ជ្រាបថានាងនៅមិនទាន់មានប្តីហើយទ្រង់ឱ្យនាងនោះឡើងជិះលើខ្នងសេះ មានពួកពល

ចោមរោមជាបរិវារ ហែហមចូលទៅកាន់ព្រះនគរ ទើបទ្រង់បញ្ជូននាងនោះត្រឡប់ទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនវិញ ។ វេលាថ្ងៃរសៀលហើយ ទ្រង់ឱ្យហែហមនាំមកអំពីត្រកូលនោះមកវិញ ដោយគ្រឿងសក្ការៈដ៏ថ្កុំថ្កើង ហើយទ្រង់អភិសេកលើគំនរកែវ តាំងជាមហេសីធំក្នុងព្រះនគរ ។ ឯមហេសីជាទីស្រឡាញ់ពេញព្រះហឫទ័យរបស់ព្រះរាជា ជាស្ត្រីស្និទ្ធស្នាលនឹងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម មាននាមប្រាកដថា ‹‹មល្លិកាទេវី›› ។

សំដែងរឿងនេះ ដើម្បីញ៉ាំងសាធុជនឱ្យជ្រាបក្នុងបិណ្ឌបាតទាន ដែលបុគ្គលបានធ្វើដល់ព្រះពុទ្ធជាម្ចាស់ជាមហន្តអតុលក្ខេត្ត ។

មានរឿងមួយទៀតថា **តេន ច សមយេន ធរមានកស្សបពុទ្ធស្ស សាសនេ ឯកោ ថេរោ អរញ្ញាវាសំ វសតិ ។**

សម័យនោះ ក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សប ទ្រង់មានព្រះជន្មាយុគង់នៅឡើយ មានព្រះថេរៈមួយអង្គនៅ

ក្នុងព្រៃជាវត្ត ។ ព្រះបរមពោធិសត្វកើតក្នុងត្រកូលគហបតី ថ្ងៃមួយ ព្រះបរមពោធិសត្វចូលទៅកាន់ព្រៃដោយការងារ របស់ខ្លួន បានឃើញព្រះថេរៈនោះ ក៏ចូលទៅជិតថ្វាយបង្គំ ហើយរមិលមើលទីកន្លែងដែលព្រះថេរៈអង្គុយ និងចង្ក្រម ជាដើម ហើយទូលសួរព្រះថេរៈថា លោកម្ចាស់មកគង់ក្នុងទី នេះឬអ្វី? ព្រះថេរៈឆ្លើយថា ចម្រើនពរឧបាសក! អាត្មាមកនៅ ក្នុងទីនេះ ។ ព្រះពោធិសត្វគិតពិចារណាថា បើអាត្មាអញធ្វើ បណ្ណសាលាប្រគេនលោកម្ចាស់ក្នុងទីនេះ យល់ថាជាការ ប្រពៃណាស់, លុះគិតដូច្នោះហើយ ក៏លះបង់ការងាររបស់ ខ្លួនចោលចេញ ចាត់ចែងគ្រឿងទព្វសម្ភារៈសាងជាបណ្ណ- សាលាមួយប្រក់ហើយស្រេច យកដីស្អិតមកលាបបូកជញ្ជាំង ហើយធ្វើឱ្យមានទ្វារបើកបិទចេញចូល ក្រាលដោយរនាប ឈើ ហើយអង្គុយក្នុងទីដ៏សមគួរ ដោយសេចក្ដីត្រិះរិះថា លោកម្ចាស់នឹងប្រើប្រាស់បណ្ណសាលានេះ ឬមិនប្រើប្រាស់ ទេ? ។ គ្រានោះ ព្រះថេរៈលោកនិមន្តមកអំពីខាងក្នុងនៃស្រុក

ហើយចូលទៅកាន់បណ្ណសាលាគង់នៅលើរនាបឈើ ។ ៦ ឧបាសកគឺពោធិសត្វ ក៏មកថ្វាយបង្គំហើយអង្គុយជិតព្រះថេរៈទូលសួរថា លោកម្ចាស់ បណ្ណសាលានេះសប្បាយឬទេ? ព្រះថេរៈឆ្លើយថា ម្នាលអ្នកមានមុខស្រស់បស់, បណ្ណសាលានេះសប្បាយណាស់ ហើយសមគួរដល់អ្នកបួសផង ។ -លោកម្ចាស់មុខជានឹងគង់នៅក្នុងទីនេះឬអ្វី?, -ម្នាលឧបាសក! មើលទៅអាត្មាប្រហែលជានៅក្នុងទីនេះហើយ ។ ឧបាសកនោះដឹងច្បាស់ថា ព្រះថេរៈទទួលនិមន្តហើយនិយាយប្តេជ្ញានឹងព្រះថេរៈថា សូមលោកម្ចាស់និមន្តទៅកាន់ទ្វារផ្ទះខ្ញុំជានិច្ច ហើយសូមពរអំពីព្រះថេរៈថា សូមលោកម្ចាស់ប្រទានពរ ១ ដល់ខ្ញុំ ។ -ម្នាលឧបាសក! ធម្មតាអ្នកបួសមានពរកន្លងអស់ហើយ គឺថាឥតមានពរអ្វីឡើយ ។ បពិត្រលោកម្ចាស់! ពរណាដែលគួរ ពរណាដែលឥតទោស ខ្ញុំសូមពរនោះឯង ។ ម្នាលឧបាសក, អ្នកចូរនិយាយចុះ! ; -បពិត្រលោកម្ចាស់ មនុស្សទាំងឡាយរមែងប្រាថ្នាចង់ឱ្យលោកម្ចាស់និមន្តទៅក្នុងលំនៅ

របស់ខ្លួនក្នុងកិច្ចការមង្គលក្តី មិនមែនជាមង្គលក្តី កាលបើលោកម្ចាស់មិននិមន្តទៅ គេក៏ខឹង, ព្រោះហេតុនោះ បើទុកជាលោកម្ចាស់ទៅកាន់ទីដែលគេនិមន្តដទៃ ក៏សូមនិមន្តទៅកាន់ផ្ទះខ្ញុំ សម្រេចភត្តកិច្ចក្នុងផ្ទះខ្ញុំកុំខាន ។ ព្រះថេរៈក៏ទទួលនិមន្តស្រេច ទើបឧបាសកនោះ យកកន្ទេលផែងទៅក្រាលយកគ្រែទៅតាំងរៀបចំក្នុងសាលា ហើយដាក់ភ្នាក់ដៃ តម្កល់ទុកគ្រឿងសម្រាប់ជូតជើង ជីកស្រះបោក្ខរណី ១ ធ្វើទីចង្រ្កម ១ យកដីខ្សាច់ទៅពោយរាយក្នុងទីនោះ កាលបើឃើញពួកសត្វម្រឹគមកត្រដុសជញ្ជាំងធ្វើដីល្អិតឱ្យធ្លាក់ចុះ ក៏យកឈើមានបន្លាមកធ្វើជារបងព័ទ្ធជុំវិញ, កាលបើឃើញពួកសត្វម្រឹគចុះទៅក្នុងស្រះបោក្ខរណី ធ្វើទឹកឱ្យល្អក់រីករវ ក៏យកថ្មទៅរៀបក្នុងស្រះ យកឈើមានបន្លាមកធ្វើជារបងព័ទ្ធអំពីខាងក្រៅជុំវិញ ហើយដាំដើមត្នោតជាជួររៀបរៀងខាងក្នុងរបង, កាលបើឃើញសត្វម្រឹគចូលមកក្នុងទីចង្រ្កម ធ្វើកន្លែងរលីងស្អាតឱ្យខូចខាតរីករវ ក៏ធ្វើរបងព័ទ្ធជុំវិញទីចង្រ្កម ហើយ

ដាំដើមត្នោតជាជួររៀបរៀងខាងក្នុងរបង, ឧបាសកញ៉ាំង អាវាសទានឱ្យសម្រេចយ៉ាងនេះហើយ ក៏ប្រគេនត្រៃចីវរ ចង្ហាន់បិណ្ឌបាត, ថ្នាំកែរោគ, ភាជនៈសម្រាប់ប្រើប្រាស់, ដែក ស្វាន, កាំបិតតូច, កាំបិតសម្រាប់កាត់ក្រចក, ម្ជុល, ឈើច្រត់, ស្បែកជើង, ល័ក្ខចាន់សម្រាប់ដាក់ទឹក, ឆ័ត្រ, អម្បែងប្រទីប, វត្ថុសម្រាប់ជម្រះនូវមន្ទិលគឺប្រែះក្អែល, បាត្រ, សៀនទឹក, សំពត់តម្រង់, ធម្មក្រក, និងប្រគេនបរិក្ខារឯទៀតៗ ដែលជា គ្រឿងប្រើប្រាស់របស់អ្នកបួសដល់ព្រះថេរៈ ។ បរិក្ខារដែល ពោធិសត្វមិនបានប្រគេនដល់ព្រះថេរៈនោះមិនមានឡើយ ។ ពោធិសត្វនោះ ក៏រក្សាសីល ធ្វើឧបោសកម្ម បំរើព្រះថេរៈអស់ មួយជីវិត ។ ព្រះថេរៈក៏បានសម្រេចព្រះអរហត្ត ហើយ បរិនិព្វានក្នុងទីនោះ ។ ពោធិសត្វខំកសាងសន្សំបុណ្យ ដរាប ដល់អស់អាយុ បានទៅកើតក្នុងទេវលោក ច្យុតអំពីទេវលោក មកកាន់មនុស្សលោកវិញ បានមកកើតក្នុងក្រុងកុសាវតីរាជ-

ធានី បានសោយរាជ្យជាស្តេច ទ្រង់ព្រះនាមថា ‹‹**មហាសុទស្សនចក្រពត្តិ**›› នោះឯង ។

អានិសង្សដែលកើតអំពីអាវាសទានជាដើម ដែលពោធិសត្វបានធ្វើមានសេចក្តីអស្ចារ្យផ្សេងៗ ដូចមានក្នុងមហាសុទស្សនសូត្រ គម្ពីរទីឃនិកាយមហាវគ្គ ។

សម្តែងរឿងនេះ ដើម្បីញុំាងសាធុជនឱ្យជ្រាបក្នុងសេនាសនទាន ដែលបុគ្គលបានធ្វើដល់ភិក្ខុក្នុងព្រះពុទ្ធសាសនា ដែលមានសេចក្តីប្រតិបត្តិបែរមុខទៅរកមគ្គផល ព្រះនិព្វាន ។

មានរឿងមួយទៀតថា **អតីតេ ពារាណសិយំ ឯកោ មច្ចុទារណិកោ អាបណេ មច្ឆំ វិក្កីណិ ។** ក្នុងកាលដែលកន្លងហើយ មានឈ្មួញលក់ទឹកឃ្មុំម្នាក់ ក្នុងក្រុងពារាណសី នៅលក់ទឹកឃ្មុំក្នុងពានផ្សារ ។ គ្រានោះ មានព្រះបច្ចេកពុទ្ធមួយអង្គកើតរោគដំបៅ ។ លំដាប់នោះ មានព្រះបច្ចេកពុទ្ធមួយអង្គទៀត ដើរស្វែងរកសូមទឹកឃ្មុំ ដើម្បីធ្វើជាថ្នាំដល់ព្រះបច្ចេកពុទ្ធនោះ លោកក៏ចុះអំពីភ្នំគន្ធមាទន៍មកកាន់នគរ

ពារាណសី ។ មាននាងកុម្ភទាសីម្នាក់ កំពុងដើរទៅកាន់កំពង់ទឹក បានឃើញព្រះបច្ចេកពុទ្ធនោះ ទូលសួរតាមដំណើរបានឮសេចក្ដីនោះសព្វគ្រប់ហើយ ក៏លាតដៃឡើងចង្អុលបង្ហាញពានផ្សារដែលលក់ទឹកឃ្មុំ ហើយទូលថា ‹‹លោកម្ចាស់ នាយឈ្មួញលក់ទឹកឃ្មុំគេនៅក្នុងទីឯណោះ សូមលោកម្ចាស់និមន្តទៅក្នុងទីនោះចុះ›› ហើយនាងក៏គិតពិចារណាថា បើនាយឈ្មួញគេមិនប្រគេនទឹកឃ្មុំដល់លោកម្ចាស់ទេ, អញនឹងទៅយកទឹកឃ្មុំប្រគេនលោកម្ចាស់ឱ្យបាន ហើយចាំស្វែងរកទ្រព្យដាតម្លៃឱ្យជាខាងក្រោយវិញ ហើយក៏ទៅឈរចាំក្នុងទីនោះ ។ ព្រះបច្ចេកពុទ្ធក៏និមន្តទៅក្នុងទីនោះឯង ។ នាយឈ្មួញបានឃើញព្រះបច្ចេកពុទ្ធនោះនិមន្តដល់ហើយ ក៏មានចិត្តត្រេកអរ ប្រគេនទឹកឃ្មុំត្រាតែពេញបាត្រ លុះឃើញទឹកឃ្មុំហូរហៀកំពប់ពីមាត់បាត្រធ្លាក់មកលើផែនដី ក៏រីងរឹតតែមានសេចក្ដីជ្រះថ្លាឡើង តាំងសេចក្ដីប្រាថ្នាថា ‹‹បពិត្រលោកម្ចាស់ ដោយអំណាចបុញ្ញកម្មនេះ ខ្ញុំសូមឱ្យបានជាស្ដេចឯករាជក្នុង

ជម្ពូទ្វីប, ម្យ៉ាងទៀត ខ្ញុំម្ចាស់សូមឱ្យមានអំណាចផ្សាយទៅក្នុងអាកាស ១ យោជន៍ ក្នុងផែនដី ១ យោជន៍›› ។ ព្រះបច្ចេកពុទ្ធមានព្រះពុទ្ធដីកាថា ម្នាលឧបាសក, ផលនៃសេចក្តីប្រាថ្នារបស់អ្នកចូរសម្រេចយ៉ាងនេះចុះ›› ហើយក៏និមន្តត្រឡប់ទៅភ្នំគន្ធមាទន៍វិញ ។ ឯនាងកុម្ភទាសីនោះ បានឃើញព្រះបច្ចេកពុទ្ធហើយទូលថា ‹‹លោកម្ចាស់បានទឹកឃ្មុំទឬទេ?›› ព្រះបច្ចេកពុទ្ធប្រាប់ថា ‹‹មើនាង! អាត្មាបានទឹកឃ្មុំហើយ, នាយឈ្មួញនោះគេបានប្រគេនដល់អាត្មាហើយ គេប្រាថ្នាជាស្តេចឯករាជក្នុងជម្ពូទ្វីប›› ។ នាងកុម្ភទាសីនោះ លុះឮពាក្យដូច្នោះហើយ ក៏ប្រាថ្នាជាអគ្គមហេសីនៃស្តេចនោះ ។ បណ្តាជនទាំងពីរនោះ នាយឈ្មួញលក់ទឹកឃ្មុំបានជាអសោក កុមារជាព្រះរាជបុត្រច្បងបង្អស់នៃព្រះរាជបុត្រទាំង ១០១ របស់ព្រះបាទពិន្ទុសាររាជ ក្នុងក្រុងបាតលីបុត្រ, លុះអំណើះឥតពីបិតាទៅហើយ ក៏សម្លាប់ប្អូនៗ ទាំងអស់ចោលចេញ ទុកតែតិស្សកុមារ ១ ដែលមានមាតាជាមួយគ្នា បានគ្រងរាជ្យសម្បត្តិ

ដោយពុំទាន់បានអភិសេក ៤ ឆ្នាំ ទើបបានរាជាភិសេកជាឯករាជ ក្នុងសកលជម្ពូទ្វីប ក្នុងរវាងពុទ្ធសករាជ ២១៨ ឆ្នាំ គិតអំពីបរិនិព្វានរនៃព្រះបរមសាស្តាមក ។ រាជឫទ្ធិទាំងអម្បាលនេះ ក៏មកដល់ព្រះរាជានោះដោយអានុភាពនៃអភិសេក ។ សេចក្តីថា រាជឫទ្ធិទាំងឡាយ ដែលស្តេចត្រូវបានដោយអានុភាបនៃបុណ្យ រមែងមកដោយអានុភាពនៃអភិសេក ដែលសម្រេចមកអំពីបយោគសម្បត្តិ ប្រៀបដូចគុណវិសេសទាំងឡាយមានបដិសម្ភិទាជាដើម រមែងមកជាមួយនឹងអរហត្តមគ្គ គឺអំណាចប្រព្រឹត្តទៅបាន ១ យោជន៍ក្នុងផែនដី ១ យោជន៍ក្នុងអាកាស ។ ពួកទេវតានាំយកទឹក ១៦ ក្អមអំពីអនោត្តស្រះមកថ្វាយសព្វៗ ថ្ងៃ នាំយកឈើស្ទន់ជាវិការៈនៃវល្លិម្លព្រៃ ដែលទន់ស្និទ្ធមានរសល្អនិងផ្លែសម៉ជាថ្នាំ ផ្លែកន្ទួតព្រៃជាថ្នាំ និងផ្លែស្វាយទុំមានសម្បុរដូចមាសបរិបូណ៌ ដោយក្លិននិងរស អំពីព្រៃហេមពាន្តមកថ្វាយសព្វៗ ថ្ងៃ ។ មួយវិញទៀត ពួកទេវតានាំយកសំពត់សម្រាប់ស្លៀក សំរាប់

ដណ្ដាប់ មានពណ៌ ៥ និងសំពត់មានពណ៌លឿង និងសំពត់សម្រាប់ជូតដៃ និងទឹកទិព្វ អំពីវិមានទេវតា ដែលតាំងនៅទៀបឆទ្ទន្តស្រះមកថ្វាយសព្វៗ ថ្ងៃ ។ ពួកនាគរាជនាំយកគ្រឿងក្រអូបសម្រាប់ផ្លូត-លាប និងសំពត់ផ្កាម្លិះ([2]) គេមិនត្បាញដោយសូត្រ([3]) ដើម្បីជាសំពត់ដណ្ដាប់ និងថ្នាំសម្រាប់លាបភ្នែក មានតម្លៃច្រើន អំពីពិភពនាគមកថ្វាយសព្វៗ ថ្ងៃ ពួកសត្វសេកនាំយកស្រូវសាលីកើតឯង ក្នុងឆទ្ទន្តស្រះចំនួន ៩ ពាន់រទេះ([4]) មកថ្វាយសព្វៗ ថ្ងៃ ។ ពួកកណ្ដុរនាំគ្នាបកស្រូវសាលីទាំងនោះធ្វើជាអង្ករ មិនឱ្យមានអង្កាមនិងកណ្ដក, អង្ករនោះមិនមានបាក់ដល់ទៅ ១ គ្រាប់ឡើយ ។ ពួកឃ្មុំនាំគ្នាមកធ្វើទឹកឃ្មុំក្នុងទីជិតបង្កើយ ។ ពួកខ្លាឃ្មុំនាំគ្នាពុះឧសក្នុងរោងដាំងដែក ។ ពួកសត្វករវិកនាំគ្នាមកចួចហួចយំប្រគំថ្វាយព្រះរាជា ប្រៀបដូចបុគ្គលអ្នកធ្វើពលិកម្ម នៅក្នុងដែនជាប្រក្រតី។

[2] -សំពត់នោះមានសាច់ម៉ដ្ឋល្អ មានក្បាច់ផ្កាម្លិះនៅក្នុងផ្ទៃសំពត់នោះ ។

[3] -សំពត់នោះកើតអំពីដើមកល្បព្រឹក្ស ជាសំពត់ទិព្វ គេមិនត្បាញដោយសូត្រអម្បោះឡើយ ។

[4] -ប្អូនក្ដាប់ដៃត្រូវជា ១ កុឌវ (កម្បង់), ៤ កុឌវ ជា ១ បត្ថ (នាឡិ), ៤ បត្ថជា ១ អាឡ្ហក, ៤ អាឡ្ហកជា ១ ទោណ, ៤ ទោណជា ១ មានិកា, ៤ មានិកា ជា ១ ខារិ (អម្រែក), ២០ ខារិជា ១ វាហ គឺ ១ រទេះ ។

នាយឈ្មួញលក់ទឹកឃ្មុំនោះ បានជាអសោកធម្មរាជ ប្រកបដោយរាជឫទ្ធិទាំងអម្បាលនេះ ដោយអំណាចឱ្យទាន ទឹកឃ្មុំសម្រាប់ជាភេសជ្ជៈដោយប្រការដូច្នេះ ។ ឯនាងកុម្ភ-ទាសីនោះ បានជាអគ្គមហេសី ទ្រង់ព្រះនាមអសន្ធិមិត្តា របស់ព្រះបាទអសោកធម្មរាជនោះ ។ បានឮថា សន្ធាក់ដៃ-ជើង របស់នាងអសន្ធិមិត្តានោះស្មើរលើងស្អាត ឥតមានប្រាកដដូច ជនដទៃឡើយ វៀរលែងតែកាលនាងបត់ចូល ដោយ អានិសង្សនៃបុញ្ញកិរិយាវត្ថុ គឺសេចក្ដីខ្វល់ខ្វាយចង្អុលប្រាប់ ផ្សារលក់ទឹកឃ្មុំនោះឯង; ព្រោះហេតុនោះ បានជាគេថ្វាយ ព្រះនាមថា «នាងអសន្ធិមិត្តា» ។

រឿងព្រះអសោកធម្មរាជនេះ មានមកក្នុងគម្ពីរទាំងឡាយ មានគម្ពីរមហាវង្សជាដើម ។ សំដែងរឿងនេះ ដើម្បីញ៉ាំង សាធុជនឱ្យជ្រាបក្នុងគិលានភេសជ្ជទាន ដែលបុគ្គលបានធ្វើ ដល់អរិយបុគ្គលជាបញ្ញក្ខេត្តដ៏វិសេស ។

**ឯវំ ចតុប្បច្ចយ ទាយកោ សុខំ វិន្ទតិ, តស្មា ទានំ សយមេវ្ង បវត្តេតព្វំ** បុគ្គលអ្នកឱ្យបច្ច័យ ៤ រមែងបានសេចក្ដីសុខ ដោយប្រការដូច្នេះ, ព្រោះហេតុនោះ អ្នកមានប្រាជ្ញាគួរញ៉ាំងទានឱ្យប្រព្រឹត្តទៅដោយខ្លួនឯង ។

ឯធម្មទាន គឺការឱ្យទានធម៌ដល់អ្នកដទៃ, បានសេចក្ដីថា បង្ហាត់បង្រៀនធម៌ដល់អ្នកដទៃ សំដែងធម៌ដល់អ្នកដទៃ សម តាមពាក្យអដ្ឋកថាចារ្យ លោកសំដែងទុកក្នុងអដ្ឋកថាអង្គុត្តរ-និកាយទុកនិបាតថា:

**ធម្មទានន្តិ ឥធេកច្ចោ អមតប្បត្តិបដិបទំ កថេត្វា ទេតិ ឥទំ ធម្មទានំ នាម** បុគ្គលពួកមួយក្នុងលោកនេះ សំដែងសេចក្ដីប្រតិបត្តិជាគ្រឿងដល់នូវព្រះនិព្វាន ឱ្យដល់អ្នកដទៃនេះហៅថា ធម្មទាន ។ ក្នុងអដ្ឋកថាឥតិវុត្តកៈថា បុគ្គលពួកមួយក្នុងលោកនេះ ចែកកុសលកម្មបថនិងអកុសលកម្មបថ ដូច្នេះថា «ធម៌នេះជាកុលស, ធម៌នេះជាអកុសល, ធម៌ប្រកបដោយទោស, ធម៌នេះមិនប្រកបដោយទោស, ធម៌នេះអ្នកប្រាជ្ញតិះដៀល, ធម៌នេះអ្នកប្រាជ្ញសរសើរ, ធម៌នេះបើបុគ្គល

ធ្វើឱ្យបរិបូណ៌ហើយ សមទានហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យ ដើម្បីសេចក្ដីទុក្ខ, ធម៌នេះប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ›› ហើយសំដែងកម្មនិងផលនៃកម្មឱ្យប្រាកដក្នុងលោកនេះ និងលោកខាងមុខ ហាក់ដូចជាចង្អុលប្រាប់ដោយជាក់ច្បាស់ និងសំដែងធម៌ញ៉ាំងជនដទៃឱ្យងាកបែរចេញអំពីអកុសលធម៌ តម្កល់នូវក្នុងកុសលធម៌នេះហៅថា ធម្មទាន ។

ពុំនោះសោត បុគ្គលឯណាសំដែងសច្ចទាំង ៤ ថា ‹‹ធម៌នេះបុគ្គលគួរត្រាស់ដឹង, ធម៌នេះបុគ្គលគួរកំណត់ដឹង(5), ធម៌នេះបុគ្គលគួរលះបង់,(6) ធម៌នេះបុគ្គលគួរធ្វើឱ្យជាក់ច្បាស,(7) ធម៌នេះបុគ្គលគួរចម្រើន(8), និងសម្ដែងធម៌គឺសេចក្ដី ប្រតិបត្តិដើម្បីបានព្រះនិព្វាន នេះ ហៅថា ‹‹ធម្មទានជា កំពូល›› ។

---

5 -កងទុក្ខ ។

6 -តណ្ហា ។

7 -ព្រះនិព្វាន ។

8 -អដ្ឋង្គិកមគ្គ ។

ម្យ៉ាងទៀត បុគ្គលដែលមអាស្រ័យនូវវិវដ្តគាមិធម្មទាន រមែងរួចចាកសេចក្តីវិនាសទាំងពួង រមែងប្រព្រឹត្តកន្លងនូវវដ្ដ-ទុក្ខទាំងអស់ ។ ចំណែកលោកិយធម្មទាន ជាហេតុនៃទានទាំង ជាមូលនៃសម្បត្តិទាំងពួង ។ ក៏បណ្តាទានទាំងនេះ អភយទានក៏សង្គ្រោះដោយធម្មទានដែរ ។ ក្នុងអដ្ឋកថាមង្គលសូត្រថា ការសម្តែងធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថាជាធម៌នាំឱ្យអស់ទៅនៃសេចក្តីទុក្ខ នាំមកនូវសេចក្តីសុខក្នុងឥធលោកនិងបរលោក ដោយសេចក្តីប្រាថ្នានូវប្រយោជន៍ដល់អ្នកដទៃ ហៅថា ‹‹ធម្មទាន›› ។

ម្យ៉ាងវិញទៀត ធម្មទានជាទានប្រសើរថ្លៃថ្លា ព្រោះឈ្នះអស់អាមិសទានទាំងពួង ។ ព្រោះហេតុនោះ បានជាព្រះមានជោគ ទ្រង់ត្រាស់សំដែងធម៌ដល់សក្កទេវរាជជាធំជាងទេវតាក្នុងតណ្ហាវគ្គនៃធម្មបទថា:

**សព្វទានំ ធម្មទានំ ជិនាតិ, សព្វរសំ ធម្មរសោ ជិនាតិ,**
**សព្វរតឹ ធម្មរតិ ជិនាតិ, តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

ធម្មទានឈ្នះអស់ទានទាំងពួង, ធម្មរសឈ្នះអស់រស់ទាំងពួង, សេចក្តីត្រេកអរក្នុងធម៌ ឈ្នះអស់សេចក្តីត្រេកអរទាំងពួង, សេចក្តីអស់ទៅនៃតណ្ហា ឈ្នះអស់ទុក្ខទាំងពួង ។

អដ្ឋកថាធិប្បាយថាៈ បើបុគ្គលឱ្យចីវរដែលដូចបណ្តូលចេកដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពដែលប្រជុំគ្នាត្រៀបត្រាឥតមានចន្លោះ ក្នុងផ្ទៃចក្រវាឡរហូតដល់ព្រហ្មលោក, នៅក្នុងទីសមាគមនោះ មានធម្មកថិកអង្គណាមួយ ធ្វើអនុមោទនាដោយគាថា ៤ បាទ ក៏ប្រសើរជាងចីវរ-ទាននោះ ។ ឯចីវរទាននោះ មិនបានមួយចំរៀកនៃគាថានោះដែលគេច្រៀកជា ១៦ ចំរៀក ១៦ ដង ។ ការសំដែងធម៌ក្តី ការបង្រៀនធម៌ក្តី ការស្តាប់ធម៌ក្តី ជាការប្រសើរយ៉ាងនេះ ។ ការស្តាប់ធម៌នោះ បើបុគ្គលឯណាបានផ្តួចផ្តើមធ្វើហើយ អានិសង្សច្រើននឹងមានដល់បុគ្គលនោះមិនខាន ។ ធម្មទានដោយហោចទៅ គ្រាន់តែបុគ្គលធ្វើអនុមោទនាដោយគាថា ៤ បាទ ក៏នៅតែប្រសើរជាងទានដែលបុគ្គលយកចង្ហាន់បិណ្ឌ-

បាតដ៏ឧត្តម ដាក់ពេញក្នុងបាត្រហើយឱ្យដល់បរិស័ទមានសភាពដូច្នោះផង([9]), ជាងកេសជ្ជទានដែលបុគ្គលយកសប្បិនិងប្រេងជាដើម ដាក់ពេញក្នុងបាត្រហើយឱ្យដល់បរិស័ទមានសភាពដូច្នោះផង, ជាងសេនាសនទាន ដែលបុគ្គលកសាងវិហារយ៉ាងមហាវិហារ កសាងប្រាសាទដូចយ៉ាងលោហប្រាសាទរាប់សែនមិនតែមួយ (ហើយឱ្យដល់បរិស័ទមានសភាពដូច្នោះផង,) ជាងបរិច្ចាគដែលអនាថបិណ្ឌិកសេដ្ឋីធ្វើប្រារព្ធនូវវិហាររបស់ខ្លួនផង ។ ព្រោះហេតុអ្វី? ព្រោះថាបុគ្គលធ្វើបុណ្យមានសភាពដូច្នោះ លុះតែបានស្តាប់ធម៌ហើយទើបធ្វើ, បើមិនបានស្តាប់ធម៌ទេមិនបានធ្វើឡើយ ។ សេចក្តីពិតថា សត្វទាំងឡាយ បើមិនបានស្តាប់ធម៌ហើយសូម្បីតែបបរមួយបោយក្តី បាយមួយវែកក្តី ក៏មិនអាចនឹងធ្វើទៅជាទានបានឡើយ ។ ធម្មទាន បានឈ្មោះថាប្រសើរជាងទានទាំងពួងដោយហេតុនេះឯង ។

[9] -ពាក្យចង្អុលទៅរកព្រះខីណាស្រពខាងដើម ។

ម្យ៉ាងទៀត លើកលែងតែព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធចេញ ព្រះថេរៈមានព្រះសារីបុត្តជាដើម ដែលប្រកបដោយបញ្ញា អាចនឹងរាប់ដំណក់ទឹកគឺគ្រាប់ភ្លៀងដែលធ្លាក់ចុះអស់កល្បទាំងមូល ក៏មិនអាចនឹងត្រាស់ដឹងនូវផលមានសោតាបត្តិផលជាដើមបានឡើយ, លុះតែបានស្តាប់ធម៌ ដែលព្រះថេរៈទាំងឡាយ មានអស្សជិតត្ថេរជាដើម លោកសំដែងហើយទើបធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលបាន ហើយធ្វើឱ្យជាក់ច្បាស់នូវសាវកបារមីញាណ ដោយធម្មទេសនាព្រះសាស្តា ។ ធម្មទាន បានឈ្មោះថា ប្រសើរដោយហេតុនេះឯង ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគសំដែងថា «**សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទាន ឈ្នះអស់ទានទាំងពួង»។

ម្យ៉ាងវិញទៀត រសទាំងពួងមានរសនៃខន្ធជាដើមក្តី រសនៃសុធាភោជនរបស់ទេវតាយ៉ាងឧក្រិដ្ឋក្តី ជាបច្ច័យនាំឱ្យលិចនៅត្រដាបត្រដួសក្នុងសង្សារវដ្ត ហើយសោយនូវសេចក្តីទុក្ខច្រើន ។ ចំណែករសនៃធម៌ ពោលគឺពោធិបក្ខិយធម៌ទាំង

៣៧ ក្តី លោកុត្តរធម៌ ៩ ក្តី ប្រសើរជាងរសទាំងពួង, ព្រោះហេតុនោះ បានជាព្រះមានព្រះភាគសំដែងថា ‹‹**សព្វរសំ ធម្មរសោ ជិនាតិ** ធម្មរស ឈ្នះអស់រសទាំងពួង›› ។

ម្យ៉ាងទៀត សេចក្តីត្រេកអរមានប្រភេទច្រើន គឺសេចក្តីត្រេកអរនឹងកូនប្រុស-ស្រី, ត្រេកអរនឹងស្រី, ល្បែងមានប៉ោ និងចម្រៀងជាដើម សេចក្តីត្រេកអរនោះ ក៏សុទ្ធតែជាបច្ច័យនាំឱ្យសត្វលិចនៅត្រដាបត្រដួសក្នុងសង្សារវដ្ត ហើយសោយនូវសេចក្តីទុក្ខជាច្រើន ។ ចំណែកសេចក្តីត្រេកអរគឺបីតិ ដែលកើតឡើងក្នុងចិត្តនៃបុគ្គលអ្នកសំដែងធម៌ក្តី អ្នកស្តាប់ធម៌ក្តី នាំឱ្យកើតសេចក្តីអណ្តែតអណ្តូងលន្ទង់លន្ទោចចិត្តក៏មាន នាំឱ្យស្រក់ហៀរហូរទឹកភ្នែកក៏មាន នាំឱ្យព្រឺព្រួចរោមក៏មាន, សេចក្តីត្រេកអរគឺបីតិនោះ អាចធ្វើនូវទីបំផុតនៃសង្សារវដ្តបាន មានព្រះអរហត្តជាទីបំផុតកិច្ច; សេចក្តីត្រេកអរក្នុងធម៌បែបនេះ ឈ្មោះថា ប្រសើរជាងសេចក្តីត្រេកអរទាំងពួង ព្រោះហេតុនោះហើយ បានជាព្រះមានព្រះភាគសំដែងថា

‹‹**សព្វរតឹ ធម្មរតិ ជិនាតិ** សេចក្តីត្រេកអរក្នុងធម៌ ឈ្នះអស់សេចក្តីត្រេកអរទាំងពួង›› ។

ម្យ៉ាងវិញទៀត សេចក្តីអស់ទៅនៃតណ្ហា បានខាងព្រះអរហត្តដែលកើតឡើងក្នុងទីបំផុតនៃកិរិយាអស់ទៅនៃតណ្ហា, ឯព្រះអរហត្តនោះ ឈ្មោះថា ប្រសើរជាងធម៌ទាំងពួង; ព្រោះហេតុនោះ បានជាព្រះដ៏មានបុណ្យ ត្រាស់សំដែងថា ‹‹**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** សេចក្តីអស់ទៅនៃតណ្ហា ឈ្នះអស់ទុក្ខទាំងពួង›› ។

ម្យ៉ាងទៀត បុគ្គលអ្នកសំដែងធម៌ ត្រូវមានចិត្តទន់ ផ្សាយនូវប្រយោជន៍ដល់អ្នកស្តាប់ មិនត្រូវគោរពក្នុងលាភឡើយ, ព្រោះថា ធម្មទានមិនបានផលច្រើនដល់បុគ្គលអ្នកសំដែងដែលគោរពក្នុងលាភនោះឡើយ, ព្រោះហេតុនោះ បានជាព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាសង្គីតិសូត្រថា អ្នកសម្តែងពួកមួយចង់ឱ្យគេស្គាល់ខ្លួនថាជាធម្មកថិក ហើយមានសេចក្តីគោរពក្នុងលាភ សំដែងធម៌ដល់អ្នកដទៃ, ធម្មកថិក

នោះមិនមានផលច្រើនឡើយ ។ អ្នកសំដែងពួកមួយមិន ប្រាថ្នាលាភសក្ការៈ ហើយសំដែងធម៌ដែលខ្លួនចេះចាំស្ទាត់ ដល់អ្នកដទៃ, ធម្មកថិននេះ ឈ្មោះថា ទេសនាមយបុញ្ញកិរិ-យាវត្ថុ ប្រែថា អំពើបុណ្យសម្រេចមកអំពីការសំដែងធម៌ ។

ម្យ៉ាងវិញទៀត បុគ្គលអ្នកសម្ដែងធម៌ ត្រូវដំកល់ធម៌ ៥ ទុកក្នុងខ្លួន, សមតាមព្រះពុទ្ធភាសិតដែលទ្រង់សំដែងទុកក្នុង គម្ពីរអង្គុត្តរនិកាយបញ្ចកនិបាតថា ម្នាលអានន្ទ! ការសំដែង ធម៌ដល់អ្នកដទៃមិនងាយឡើយ! ម្នាលអានន្ទ! បុគ្គលអ្នក សំដែងធម៌ដល់អ្នកដទៃ គួរតម្កល់ធម៌ ៥ ប្រការទុកក្នុងចិត្ត ហើយទើបសំដែងធម៌ដល់អ្នកដទៃបាន, ធម៌ ៥ ប្រការនោះគឺ

**១-អនុបុព្វីកថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា អាត្មាអញនឹង សម្ដែងធម្មកថាជាលំដាប់ គឺសីលជាលំដាប់នៃទាន, ស្ថាន សួគ៌ជាលំដាប់នៃសីលជាដើម និងសំដែងធម្មកថាសមគួរ ដល់សូត្រនិងគាថានោះៗ;

**២-បរិយាយំ ទស្សាមិ**([10]) **កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា អាត្មាអញនិងចង្អុលប្រាប់ហេតុនៃអត្ថនោះៗហើយសំដែងធម្មកថា;*

**៣-អនុទ្ទយតំ បដិច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា អាត្មាអញនឹងសំដែងធម្មកថា អាស្រ័យសេចក្ដីអនុគ្រោះ គឺមានបំណងនឹងដោះសត្វដែលជាប់ជំពាក់ ដោយសេចក្ដីចង្អៀតជំឱ្យរួចអំពីសេចក្ដីចង្អៀតចេញ;*

**៤-ន អាមិសន្តរោ កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា អាត្មាអញមិនមានអាមិសជាហេតុ គឺថាមិនប្រាថ្នានូវលាភគឺបច្ច័យ ៤ ហើយសំដែងនូវធម្មកថា;*

**៥-អត្តានញ្ច បរញ្ច អនុបហច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា*

---

[10] -កន្លែងខ្លះថា បរិយាយ ទស្សាវី ។

អាត្មាអញមិនបានបៀតបៀនខ្លួនឯង([11]) និងអ្នកដទៃហើយ សំដែងធម្មកថា ។

ការឱ្យអាមិសជាទានក្តី សំដែងធម៌ឬបង្ហាត់បង្រៀនដល់អ្នកដទៃក្តី ឈ្មោះថា ទានមយៈៗ នេះចាត់ជាបុញ្ញកិរិយាវត្ថុមួយក្នុងព្រះពុទ្ធសាសនា ។

សីលមយៈ បុណ្យសម្រេចដោយការរក្សាសីល ។ សីលនោះចែកទៅមានច្រើនប្រការ, តែក្នុងទីនេះ សូមលើកយកតែសីល ៥ មកអធិប្បាយជាតួយ៉ាង; ឯសីល ៥ នោះ ដូចមានក្នុងបាលីសង្គីតិសូត្រ គម្ពីរទីឃនិកាយ បាដកវគ្គថា **បញ្ច សិក្ខាបទានិ បាណាតិបាតា វេរមណី, អទិន្នាទានា វេរមណី, កាមេសុ មិច្ឆាចារា វេរមណី, មុសាវាទា វេរមណី, សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** = សិក្ខាបទទាំងឡាយ ៥ គឺ ការវៀរចាកសម្លាប់សត្វ ១, ការវៀរលួចទ្រព្យគេ ១, ការវៀរប្រព្រឹត្តខុសក្នុងកាមគឺសេពមេថុនធម្មនឹងស្ត្រី ២០ ជំពូក

[11] -មិនបានប៉ះពាល់ខ្លួនឯង និងអ្នកដៃ គឺមិនលើកដំកើងខ្លួនឯងហើយបង្អាប់បង្អោនអ្នកដទៃជាដើម ។

១, ការវៀរនិយាយពាក្យកុហក ១, ការវៀរហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ១ ។

បើនឹងសំដែងដោយសេចក្តី ពាក្យថាវៀរនោះ បានដល់វិរតិគឺការវៀរដែលប្រកបដោយកុសលចិត្ត ។ ក៏ឯវិរតិនោះមាន ៣ ប្រការ គឺ សម្បត្តិវិរតិ ១, សមាទានវិរតិ ១, សមុច្ឆេទ-វិរតិ ១ ។

សម្បត្តិវិរតិ បានដល់ការវៀរដែលកើតឡើងដល់បុគ្គលដែលមិនបានសមាទានសិក្ខាបទហើយមិនប្រព្រឹត្តកន្លងនូវវត្ថុដែលមកដល់ក្នុងទីចំពោះមុខ គឺជួបប្រទះនឹងសត្វគួរសម្លាប់មិនសម្លាប់, ទ្រព្យគេគួរលួចមិនលួចជាដើម ដោយពិចារណាឃើញនូវជាតិនិងវ័យ និងសេចក្តីចេះដឹងរបស់ខ្លួនជាដើម, មួយវិញទៀត គិតឃើញថា អំពើសម្លាប់សត្វជាដើមនេះ មិនសមគួរដល់អាត្មាអញឡើយ ដូចវិរតិចក្កនឧបាសក អ្នកនៅក្នុងលង្កាទ្វីប ។ មានរឿងដំណាលថា កាលឧបាសកនោះក្មេងនៅឡើយ រោគក៏កើតមានឡើងដល់មាតារបស់ឧបាសក

នោះៗ ក៏យកពេទ្យមកព្យាបាលរក្សាមើលមាតានោះ, ពេទ្យគេនិយាយថា រោគនេះត្រូវនិងថ្នាំសាច់ទន្សាយស្រស់ ។ ទើបបងប្រើចក្កុនឧបាសកនោះ ឱ្យទៅរកសាច់ទន្សាយស្រស់ឯស្រែ ។ ចក្កុនឧបាសកក៏ដើរទៅស្រែនោះ ។ ក្នុងសម័យនោះមានសត្វទន្សាយមួយដើរមកដើម្បីទំពាស៊ីសន្ទូងខ្ចី ។ ទន្សាយបានឃើញចក្កុនឧបាសកនោះហើយ ក៏បោលប្រញាប់ទៅព័ទ្ធនឹងវល្លិទៅណាពុំរួច ប្រឹងស្រែកបម្រះនទៀលទៅមកក្នុងទីនោះ ។ ចក្កុនឧបាសកបានឮសម្លេងនោះហើយ ក៏ស្ទុះទៅចាប់បានយកមកដោយគិតថា នឹងធ្វើថ្នាំដល់មាតារបស់ខ្លួន, ក៏គិតម្តងទៀតថា អាត្មាអញមិនគួរនឹងសម្លាប់ជីវិតគេព្រោះជីវិតមាតារសប់ខ្លួនដូច្នេះឡើយ ។ ទើបចក្កុនឧបាសកលែងទន្សាយនោះទៅ និយាយថា ទន្សាយឯងចូរទៅបរិភោគស្មៅនិងទឹកជាមួយនឹងទន្សាយឯទៀតចុះ ។ លុះចក្កុនឧបាសកត្រឡប់មកផ្ទះវិញ បងក៏សួរថា បានទន្សាយឬទេ? ក៏ឆ្លើយប្រាប់តាមដំណើរនោះសព្វគ្រប់ដល់បង ។ បងក៏គម្រាមចក្ក-

នឧបាសកនោះតាមអំពើចិត្ត ។ ចក្កុនឧបាសកក៏ទៅកាន់សំណាក់មាតារបស់ខ្លួន ហើយពោលសច្ចវាចាថា អាត្មាអញតាំងពីកើតមក មិនដែលមានចិត្តក្លែងញ៉ាំងសត្វឱ្យធ្លាក់ចុះចាកជីវិតឡើយ ។ មាតាចក្កុនឧបាសកនោះ ក៏ជារោគភ្លាមមួយរំពេច សម្បត្តិវិរតិ មានសេចក្ដីសង្ខេបយ៉ាងនេះ ។

សមាទានវិរតិ គឺវិរតិដែលកើតឡើងដល់បុគ្គលដែលបានសមាទានសិក្ខាបទហើយស៊ូលះបង់ជីវិតខ្លួន មិនហ៊ានប្រព្រឹត្តឱ្យកន្លងវត្ថុ គឺសត្វគួរនឹងសម្លាប់ និងទ្រព្យគេគួរលួចមិនលួចជាដើម ដូចវិរតិរបស់ឧបាសកម្នាក់នៅក្នុងទន្តវឌ្ឍនគ្រាម ។ មានសេចក្ដីដំណាលថា ឧបាសកនោះ បានសមាទានសិក្ខា-បទក្នុងសំណាក់ព្រះបិង្គលពុទ្ធរក្ខិតត្ថេរ ហើយក៏ទៅភ្ជួរស្រែ ។ លុះកាលជាខាងក្រោយមក គោរបស់ឧបាសកនោះក៏បាត់ទៅ ។ ឧបាសកនោះដើរស្វែងរកគោរនោះ ឡើងទៅរកលើភ្នំឈ្មោះទន្តវឌ្ឍគ្រាម ។ មានពស់ថ្លាន់មួយធំ រួបរឹតឧបាសកនោះនៅលើភ្នំនោះឯង ។ ឯឧបាសកនោះគិតថា អាត្មាអញ

កាត់ក្បាលពស់ថ្វាន់ដោយកាំបិតព្រាដ៏មុតនេះ ក៏គិតម្ដងទៀតថា អាត្មាអញបានសមាទានសិក្ខាបទក្នុងសំណាក់គ្រូដែលមានកេរ្តិ៍ឈ្មោះប្រសើរហើយ មិនគួរនឹងទម្លាយសិក្ខាបទនោះសោះ, លុះគិតដូច្នោះ ៣ ដងហើយ ក៏គិតម្ដងទៀតថា អាត្មាអញលះបង់ជីវិតខ្លួនចុះ, មិនគួរលះបង់សិក្ខាបទទេ, ហើយក៏បោះកាំបិតព្រា ដែលនៅលើស្មាចោលទៅក្នុងព្រៃ ។ ឯពស់ថ្វាន់ក៏លែងឧបាសកនោះ ហើយលូនចេញទៅមួយរំពេច ។ សមាទានវិរតិ មានសេចក្ដីសង្ខេបយ៉ាងនេះ ។

ឯសមុច្ឆេទវិរតិ បានដល់វិរតិដែលប្រកបដោយអរិយមគ្គរបស់ព្រះអរិយបុគ្គល ចាប់ដើមតាំងអំពីកើតសមុច្ឆេទវិរតិនោះឡើង សន្ដានចិត្តរបស់ព្រះអរិយបុគ្គលនោះ មិនបានគិតនិងសម្លាប់សត្វឡើយ ។

ម្យ៉ាងទៀត ជនជាសប្បុរសប្រកបដោយបញ្ញាល្អ គួររក្សាសីល ៥ កាលបើបានរក្សាហើយ ត្រូវប្រព្រឹត្តឱ្យល្អក្នុងសីលនោះ កុំឱ្យដាច់ដាចធ្លុះធ្លាយ, កាលបើនឹងបរិភោគអាហារ គួរ

បរិភោគឱ្យបរិសុទ្ធដោយទីបំផុតទាំង ៣ គឺ មិនបានឃើញ ១, មិនបានឮ ១, មិនបានរង្កៀស ១ គួរតែលះបង់ជីវិតខ្លួន មិនគួរប្រព្រឹត្តឱ្យកន្ទង់សីលនោះឡើយ, ដូចមានរឿងដំណាលថា ព្រះរាជាមួយព្រះអង្គ សោយរាជ្យក្នុងលង្កាទ្វីប ទ្រង់ព្រះនាមថា ‹‹ធម្មិកតិស្សមហារាជ››, ព្រះរាជាអង្គនោះ ទ្រង់មានព្រះរាជហឫទ័យចង់សោយសាច់ទទាអាំង តែទ្រង់ព្រះចិន្តាថា បើអញនិយាយប្រាប់គេថាចង់ស៊ីសាច់ទទាអាំងហើយ មុខតែជនទាំងឡាយនឹងធ្វើសត្វទទាឱ្យវិនាស ក្នុងទីប្រមាណជាមួយយោជន៍ជុំវិញ ។ ព្រះរាជាអង្គនោះ ក៏ទ្រង់អត់ទ្រាំសេចក្តីស្រេកឃ្លានអស់ ៣ ឆ្នាំ មានរោគខ្ទុះកើតក្នុងព្រះកាណ៌ ។ ព្រះអង្គក៏មិនអាចអត់ទ្រាំសេចក្តីស្រេកឃ្លានបាន ក៏មានព្រះបន្ទូលសួរថា ‹‹មនុស្សណាមួយជាខ្ញុំបម្រើរបស់អញ ហើយជាអ្នករក្សាសីលដោយត្រឹមត្រូវមានដែរឬទេ?›› ជនទាំងឡាយក្រាបទូលថា ‹‹សូមទ្រង់ព្រះមេត្តាប្រោស, មានឧបាសកម្នាក់ឈ្មោះតិស្ស រក្សាសីលត្រឹមត្រូវមិនឱ្យដាច់ធ្លុះធ្លាយឡើយ›› ។

ព្រះរាជទ្រង់ប្រាថ្នានឹងល្បងឧបាសកនោះ ទ្រង់បង្គាប់ឱ្យហៅឧបាសកនោះមក ។ ឧបាសកនោះក៏មកតាមព្រះរាជអាជ្ញា ដល់ហើយក៏ក្រាបបង្គំ ស្ថិតនៅក្នុងទីដ៏គួរសម ។ ព្រះរាជាទ្រង់សួរថា «អ្នកឯងឈ្មោះតិស្សឧបាសកឬ? -ព្រះករុណាថ្លៃវិសេស» ។ ព្រះរាជាទ្រង់ត្រាស់ថា «អ្នកឯងចូរត្រឡប់ទៅវិញចុះ», ឧបាសកនោះក៏ត្រឡប់ទៅវិញ ព្រះរាជទ្រង់បង្គាប់បុរសម្នាក់ ឱ្យយកមាន់រស់ ១ ទៅឱ្យឧបាសកនោះចំអិនក្រយាស្ងោយ ៣ មុខយកមកថ្វាយព្រះអង្គ ។ បុរសនោះក៏ទៅតាមព្រះរាជបង្គាប់ ។ ឧបាសកនោះបាននិយាយនឹងព្រះរាជបំរើនោះថា «បើមាន់នេះងាប់ស្រាប់, យើងអាចនឹងចាត់ចែងក្រយាស្ងោយតាមព្រះរាជហឫទ័យ, ឥឡូវនេះមាន់នៅរស់យើងធ្វើមិនបានឡើយ ព្រោះយើងមិនសម្លាប់សត្វ» ។ រាជ-បម្រើក៏ត្រឡប់មកក្រាបបង្គំទូលព្រះរាជានោះវិញ; ព្រះរាជាក៏ទ្រង់បង្គាប់ឱ្យរាជបំរើទៅប្រាប់ដូច្នោះទៀត, រាជបម្រើទៅប្រាប់ឧបាសកនោះម្តងទៀតថា «ការបម្រើព្រះរាជាជាការ

ធ្ងន់ពន់ពេកណាស់, អ្នកឯងកុំធ្វើដូច្នេះឡើយ, កាលបើសីលដាច់ទៅហើយ អ្នកឯងអាចនឹងសមាទានវិញទៀតបាន; អ្នកឯងចូរចំអិនមាននេះថ្វាយព្រះរាជាកុំខាន›› ។ គ្រានោះ តិស្សឧបាសកនិយាយទៅនឹងរាជបំរើថា ‹‹ក្នុងអត្តភាពមួយមានសេចក្តីស្លាប់ម្តងទៀងឥតឃ្មៀងឃ្លាតឡើយ ហេតុនោះ យើងមិនធ្វើបាណាតិបាតទេ!›› ។ រាជបម្រើក៏ត្រឡប់ទៅក្រាបបង្គំទូលព្រះរាជាវិញ ។ ព្រះរាជាក៏ប្រើរាជបំរើទៅដូច្នោះដាគំរប់បីដង; ឧបាសកនោះក៏នៅតែមិនព្រមទទួលធ្វើតាមព្រះរាជអាជ្ញា ទើបទ្រង់ឱ្យហៅឧបាសកនោះមកទ្រង់សួរដោយព្រះអង្គឯង ។ ឧបាសកនោះ ក៏នៅតែរឹងទទឹងនឹងព្រះរាជអាជ្ញាដូច្នោះដដែល ។ ព្រះរាជាទ្រង់បង្គាប់រាជបុរសថា ‹‹ឧបាសកនេះ វាមិនទទួលធ្វើតាមព្រះរាជអាជ្ញា, អ្នកទាំងឡាយចូរនាំវាទៅដាក់ត្រង់កន្លែងសម្លាប់មនុស្ស ហើយកាត់ក្បាលចោលចេញ››; តែទ្រង់ឱ្យសញ្ញាដល់រាជបុរសក្នុងទីស្ងាត់ថា អ្នកទាំងឡាយកុំអាលសម្លាប់វា គ្រាន់តែគម្រាមឱ្យវាខ្លាចហើយ

នាំវាទៅយកក្បាលវាដំកល់ទុកលើជ្រញ់កន្លែងសម្ងាប់មនុស្ស ហើយត្រឡប់មកប្រាប់អញវិញ ។ ពួករាជបុរសនាំឧបាសកនោះទៅឱ្យដេកលើជ្រញ់កន្លែងសម្លាប់មនុស្ស ហើយយកមាន់នោះទៅដាក់លើដៃឧបាសកៗ ក៏យកមាន់ដាក់លើទ្រូងរបស់ខ្លួន ហើយនិយាយថា ‹‹ម្នាលមាន់! អញឱ្យជីវិតអញដល់ឯង យកជីវិតឯងមកជាជីវិតអញវិញ, មានឯងកុំភិតភ័យអ្វី ! ឯងចូរទៅចុះ›› ថាដូច្នោះហើយក៏លែងមាន់នោះទៅ ។ មាន់ក៏ទទះស្លាបហើយទៅទំលើដើមជ្រៃ ១; កន្លែងនេះជាកន្លែងឱ្យអភ័យដល់សត្វមាន់ មានឈ្មោះប្រាកដថា ‹‹កុក្កុដគិរី›› ។

ឯព្រះរាជា ទ្រង់ព្រះសណ្ដាប់ដំណឹងនោះហើយ ទ្រង់បង្គាប់បុត្រីនៃអាមាត្យម្នាក់ ឱ្យហៅឧបាសកនោះមកវិញ ហើយទ្រង់ព្រះរាជទាន បំពាក់គ្រឿងប្រដាប់ទាំងពួងដល់ឧបាសក ហើយទ្រង់មានព្រះបន្ទូលថា ‹‹យើងមិនបានធ្វើទុក្ខទោសអ្វីដល់អ្នកឯងទេ, យើងគ្រាន់តែល្បងអ្នកឯងមើលទេ,

ព្រោះយើងមានប្រាថ្នាចង់សោយសាច់សត្វទទាកន្ទង់ ៣ ឆ្នាំមកហើយ, អ្នកឯងអាចចាត់ចែងសាច់សត្វទទាដែលបរិសុទ្ធដោយទីបំផុត ៣ យ៉ាងឱ្យយើងបានឬទេ?›› ឧបាសកទទួលព្រះបន្ទូលរួចហើយក៏ចេញទៅឈរទៀបមាត់ទ្វារ ស្រាប់តែឃើញបុរសម្នាក់យួរសត្វទទាងាប់ស្រាប់ ៣ ដើរចូលមកអំពីព្រឹក បានឱ្យថ្លៃពីរកហាបណ ទិញយកទទានោះមកចាត់ចែងធ្វើបង់គ្រឿងប្រហើរមានជីរជាដើម អាំងឆ្អិនស្រេច ក៏នាំយកមកថ្វាយព្រះរាជា ។ រឿងនេះមានមកក្នុងអដ្ឋកថាអាសិវិសវគ្គក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ។

ម្យ៉ាងវិញទៀត សីល ៥ បើបុគ្គលឯណាបានរក្សាដោយប្រពៃហើយ, បុគ្គលនោះឈ្មោះថា ជាអ្នកមានសីល ហើយរមែងទៅកើតក្នុងសុគតិភព; សមតាមពុទ្ធភាសិត ដែលព្រះអង្គទ្រង់ប្រោសព្រះរាជទានធម៌ទេសនា ដល់អនាថបិណ្ឌិកសេដ្ឋី ក្នុងគម្ពីរអង្គុត្តរនិកាយបញ្ចកនិបាតថា:

**យោ បាណំ នាតិបាតេតិ មុសាវាទំ ន ភាសតិ**

**លោកេ អទិន្នំ អាទិយតិ បរទារំ ន គច្ឆតិ**

**សុរាមេរយបានញ្ចា យោ នរោ នានុយុញ្ជាតិ**
**បហាយ បញ្ច វេរានិ សីលវា ឥតិ វុច្ចតិ**
**កាយស្ស ភេទា សប្បញ្ញោ សុគតឹ សោបបជ្ជតិ ។**

ជនឯណាមិនសម្លាប់សត្វ, មិននិយាយពាក្យកុហក, មិនកាន់យកទ្រព្យដែលគេមិនបានឱ្យក្នុងលោក, មិនសេពគប់នឹងភរិយារបស់អ្នកដទៃ, ម្យ៉ាងទៀត ជនឯណាមិនប្រកបនូវការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ; ជននោះឈ្មោះថាបានលះបង់ពៀរទាំង ៥ ហើយ, អ្នកប្រាជ្ញឱ្យឈ្មោះថាជាអ្នកមានសីល, ជននោះប្រកបដោយបញ្ញា លុះរំលាយបញ្ចក្ខន្ធទៅហើយ រមែងចូលទៅកាន់សុគតិភព ។

មួយទៀត បុគ្គលដែលបានសមាទានកាន់តាមសិក្ខាបទឱ្យបរិបូណ៌ ដូចពោលមកហើយនោះ រមែងបាននូវអានិសង្ស ទាំង ៥ ប្រការគឺៈ

១-រមែងបាននូវគំនរនៃភោគសម្បទ៏ដ៏ស្តុកស្តម្ភ;

២-រមែងមានកិត្តិសព្ទដ៏ពីរោះផ្សាយទៅសព្វទិស;

៣-ទោះចូលទៅកាន់ទីសមាគមណាៗ រមែងមិនមានមុខឱនចុះ;

៤-ជាអ្នកមិនវង្វេងដល់កាលទៀបនឹងមរណកាល;

៥-កាលបើធ្វើកាលកិរិយាពីលោកនេះទៅហើយ រមែងចូលទៅកាន់សុគតិភពដោយពិតប្រាកដ ។

ជនជាសប្បុរសប្រកបដោយបញ្ញា កាលបើឃើញអានិសង្សសីល ដែលបុគ្គលបានសមាទានតាមសិក្ខាបទដែលពោលរួចមកហើយនោះ, គួរវៀសវៃប្រញាប់ប្រញាល់រក្សាសីលកុំខាន ។ សីលដែលពោលមកប៉ុណ្ណោះជាដើមចាត់ជាបុញ្ញកិរិយាវត្ថុមួយក្នុងព្រះពុទ្ធសាសនា ។

ឯភាវនាមយៈ បុណ្យសម្រេចដោយការចម្រើនភាវនានោះ, ភាវនា ប្រែថា «ចម្រើន, អប់រំ», ប៉ុណ្ណោះជាដើម ក្នុងទីនេះមិនបានអធិប្បាយឱ្យពិស្ដារទេ ព្រោះមានក្នុងសៀវភៅឯទៀតជាច្រើនហើយ; ហេតុនេះ លោកអ្នកសិក្សាគប្បីមើលក្នុងសៀវភៅនោះៗ ឱ្យបានចូលចិត្តផងចុះ ។

## និគមវចនៈ

*ការបរិច្ចាគទាន រក្សាសីល និងចំរើនភាវនា ហៅថា ការបំពេញបុណ្យ ។ ពាក្យថា «បុណ្យ» បានដល់ធម្មជាតិដែលជម្រះចិត្តឱ្យហ្មត់ចត់បរិសុទ្ធ ដូចជាអ្នកដែលបំពេញទានរមែងមានសេចក្តីរីករាយ ថាខ្លួនបានធ្វើកិច្ចដ៏ប្រពៃ, អ្នករក្សាសីល រមែងមានសេចក្តីត្រជាក់ចិត្ត មិនមានវិប្បដិសារក្តៅក្រហាយ ព្រោះកាយ វាចា រមែងពិចារណាឃើញសេចក្តីពិតព្រមទាំងបានទទួលសុខដ៏សុខុម ។*

*មួយទៀត ពាក្យថា «បុណ្យ» នេះ បានទាំងហេតុទាំងផល គឺៈ អលោភៈ, អទោសៈ, អមោហៈ ហៅថា បុណ្យជាហេតុ, សេចក្តីល្អដែលកើតអំពីសេចក្តីមិនលោភ, មិនក្រោធ, មិនវង្វេង ហៅថា បុណ្យជាផល ។*

*ន័យមួយទៀត ពាក្យថា «បុណ្យ» នេះជាផលនៃសេចក្តីសុខ, សេចក្តីរីករាយសប្បាយចិត្តក៏ដោយ, សេចក្តីត្រជាក់ចិត្តក៏ដោយ, ជាពាក្យវេវចនៈផ្លាស់ប្តូរគ្នានិងសេចក្តីសុខ ដែល*

កើតអំពីការធ្វើនូវអំពើដែលប្រាសចាកទោសគ្រប់យ៉ាង រួមខ្លី មក ហៅថា ‹‹បុណ្យ›› ។

## សាមញ្ញលក្ខណៈ ៣ យ៉ាង (16)

លក្ខណៈដែលមានស្មើទូទៅដល់សង្ខារទាំងពួង ហៅថា ‹‹សាមញ្ញលក្ខណៈ›› ឬ ‹‹ត្រៃលក្ខណៈ›› ក៏ហៅបាន ចែកជា ៣ យ៉ាងគឺ:

**១-អនិច្ចតា** សភាពមិនទៀង:

**២-ទុក្ខតា** សភាពជាទុក្ខ;

**៣-អនត្តតា** សភាពជារបស់មិនមែនខ្លួន ។

អធិប្បាយថា:

ឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណគ្រប់គ្រង ដូចជាមនុស្សនិងសត្វតិរច្ឆានជាដើម, សូម្បីមានពណ៌សម្បុរ ស ខ្មៅ វែង ខ្លី ខ្ពស់ ទាប ផ្សេងគ្នាយ៉ាងណាក៏ដោយចុះ រមែង

ធ្លាក់ទៅក្នុងអំណាចលក្ខណៈទាំង ៣ យ៉ាងគឺ មិនទៀង, ជាទុក្ខ, ជាអនត្តា ។ សមដូចនិទានដំណាលថាៈ

ទ្រព្យសម្បត្តិ ៤០ កោដិ របស់សេដ្ឋីក្នុងក្រុងសាវត្ថីម្នាក់ក្លាយទៅជាធ្យូងទាំងអស់ ។ សេដ្ឋីនោះមានសេចក្ដីទុក្ខយ៉ាងខ្លាំង ហើយដេកសោកស្ដាយទ្រព្យសម្បត្តិលើគ្រែ ។ សម័យនោះ មានសម្លាញ់សេដ្ឋីនោះម្នាក់បានមកលេង លុះឃើញហេតុដូច្នោះហើយក៏សួរថា ‹‹ម្នាលសម្លាញ់! ព្រោះហេតុអ្វីបានជាអ្នកកើតទុក្ខដេកស្ដូកស្ដឹងដល់ម្ល៉េះ?›› សេដ្ឋីបានឮសម្លាញ់សួរដូច្នោះហើយក៏ពោលថា ‹‹អើសំឡាញ់! ខ្ញុំកើតទុក្ខព្រោះតែទ្រព្យសម្បត្តិទាំងអស់ក្លាយទៅជាធ្យូង››, -មែនឬសម្លាញ់! -មែនសម្លាញ់! -អើបើដូច្នោះអ្នកកុំភ័យអ្វីឡើយ, ចាំខ្ញុំរកឧបាយកលមួយប្រាប់អ្នក, ឱ្យតែអ្នកព្រមធ្វើតាមខ្ញុំ; -ខ្ញុំធ្វើតាមសំឡាញ់! ចូរអ្នកប្រាប់មកមើល! -បើដូច្នោះ ចូរអ្នកឯងយកកន្ទេលតូចមួយទៅក្រាលក្នុងពានផ្សារ ហើយប្រមូលទ្រព្យទាំងនោះទៅចាក់ជារគរលើកន្ទេល ហើយអង្គុយឱ្យដូច

ជាបុគ្គលអង្គុយលក់អីវ៉ាន់ក្នុងផ្សារ; កាលបើធ្វើយ៉ាងនេះ ហើយជនទាំងឡាយដែលចូលទិញវត្ថុក្នុងផ្សារ ជនណាមួយ ដែលពោលថា ម្នាលអ្នក, ជនដ៏សេសទាំងឡាយគេលក់ប្រេង ទឹកឃ្មុំ, ស្ករអំពៅជាដើម, ចុះអ្នកមកអង្គុយលក់ធ្យូងដូច្នេះ វិញ? យ៉ាងនេះត្រូវអ្នកឯងនិយាយថា ខ្ញុំអង្គុយលក់វត្ថុរបស់ ខ្ញុំ, អ្នកឯងម៉េចក៏និយាយយ៉ាងនេះ? ; ម្យ៉ាងទៀត បើជនទាំង នោះ ជនណាមួយដើរមកហើយពោលថា ម្នាលអ្នកមានមុខ ដ៏ស្រស់បស់, ជនទាំងឡាយ ជនទាំងឡាយគេលក់វត្ថុមាន ប្រេងនិងទឹកឃ្មុំជាដើម, ប្លែកអ្វីម្ល៉េះតែអ្នក យកមាសមកចាក់ គរលើកន្ទេលអង្គុយលក់ដូច្នេះ? នោះអ្នកឯងត្រូវចាប់អ្នក នោះមកសួរថា ត្រង់ណាប្រាក់និងមាស? ចូរអ្នកចាប់លើក មកឱ្យខ្ញុំមើល? កាលបើជននោះ ចាប់យកមកហើយ ត្រូវអ្នក ទទួលពីដៃជននោះ; វត្ថុទាំងនោះនឹងក្លាយទៅជាមាសប្រាក់ ទាំងអស់ ហើយត្រូវចាប់ជននោះទុកក្នុងទីនោះសិន; បើសិន ជាស្រីត្រូវនាំស្ត្រីនោះមកផ្សំផ្គុំនិងបុត្ររបស់អ្នក, បើជាប្រុស

វិញ ក៏ត្រូវអ្នកឯងចាប់យកមកផ្សំផ្គុំជាមួយនិងធីតារបស់អ្នកកុំខាន ហើយប្រគល់វត្ថុទាំងនោះឱ្យជននោះចុះ, អ្នកឯងត្រូវរស់នៅដោយសារជននោះ» ។ សេដ្ឋីបានស្តាប់ឧបាយកលដែលសំឡាញ់ប្រាប់ដូច្នោះហើយ ក៏ពោលថា «ម្នាកសម្លាញ់! ឧបាយកលរបស់អ្នកនេះប្រសើរពេកណាស» ។ សេដ្ឋីក៏ធ្វើតាមដូច្នោះមែន ។ ក្នុងពេលនោះ មាននាងកុមារិកាម្នាក់ឈ្មោះគោតមី ជាធីតារបស់ត្រកូលអ្នកមានជាន់ចាស់ម្នាក់បានធ្វើដំណើរទៅក្នុងពានផ្សារនោះ លុះឃើញសេដ្ឋីដូច្នោះហើយ ក៏សួរថា «ម្នាលអ្នកដ៏ចម្រើន! ជនដ៏សេសទាំងឡាយគេតែងលក់ដូរវត្ថុមានសំពត់, ប្រេង, ទឹកឃ្មុំ ជាដើម ប៉ុន្តែអ្នកមកអង្គុយលក់ប្រាក់និងមាសដូច្នេះ?» ; សេដ្ឋីសួរថា «ត្រង់ណាមាសនិងប្រាក់ ចូរនាងយកមកមើល?» នាងគោតមី ក៏លូកដៃទៅចាប់យកប្រាក់ និងមាសដែលសេដ្ឋីនោះគរក្បែរមុខហើយឱ្យដល់សេដ្ឋីនោះ, វត្ថុទាំងនោះក៏ក្លាយទៅជាប្រាក់និងមាស ក្នុងខណៈដែលនាងចាប់កាន់ឡើងលើ

ហើយហុចដល់មហាសេដ្ឋី ។ សេដ្ឋីសួរថា «នាងនៅទីកន្លែងភូមិ-ស្រុក-ជនបទត្រង់ណា? -ខ្ញុំនៅស្រុកឯណោះ; សេដ្ឋីដឹងថានាងនោះនៅមិនទាន់មានប្ដីដូច្នោះ ក៏នាំនាងមកផ្សំផ្គុំជាមួយនិងកូនប្រុសរបស់ខ្លួន ហើយបានប្រគល់ទ្រព្យសម្បត្តិទាំងនោះចំពោះកូនប្រសាទាំងអស់ ។ ព្រោះហេតុហ្នឹងហើយបានជាជនទាំងឡាយគេស្គាល់ឈ្មោះនាងថា «កីសាគោតមី» ដូច្នេះ មកពីនាងមានរាងរៅស្គមបន្តិច ។

សម័យខាងក្រោយមក នាងកុមារិកានោះក៏មានភគ៌ដំកលនៅក្នុងផ្ទៃ, កាលណាបើគ្រប់ ១០ ខែហើយក៏សម្រាលមក ។ បុត្រនោះគ្រាន់តែកើតមកដរាបចេះដើរ ក៏ស្លាប់ទៅ ។ ឯនាងកីសាគោតមី ក៏កើតទុក្ខទោមនស្សក្នុងចិត្តជាពន់ពេកមិនអាចអត់ទ្រាំនឹងសេចក្ដីទុក្ខ ក៏ដើរពកូនស្លាប់ដើម្បីនឹងរកថ្នាំមើលកូននោះ ។ នាងក៏ខំប្រឹងពកូនដើររកថ្នាំដរាបដល់ភូមិមួយហើយស្រែកសួរគេថា «មានអ្នកណាចេះថ្នាំមើលជម្ងឺបុត្ររបស់ខ្ញុំដែលស្លាប់ហើយនេះដែរឬទេ?» មនុស្សទាំង

ឡាយពោលថា «នាងឯងឆ្កួតទេ បានជាដើរពកូនស្លាប់រកថ្នាំដូច្នេះ?» នាងក៏នៅតែមិនធ្វើជាដឹងនឹងពាក្យសំដីរបស់មនុស្សទាំងនោះ ។ លំដាប់នោះ មានបណ្ឌិតបុរសម្នាក់បានឃើញនាងជាក់ហើយ គិតថាស្ត្រីនេះ មានសេចក្តីទុក្ខព្រោះតែបុត្ររបស់ខ្លួនស្លាប់តើ? បើដូច្នោះ មានតែអញរកឧបាយមួយប្រាប់នាង ដើម្បីឱ្យផុតអំពីសេចក្តីទុក្ខនេះ ហើយក៏ប្រាប់ថា «ម្នាលនាងដ៏ចម្រើន, ខ្ញុំដឹងបុគ្គលអ្នកចេះថ្នាំបែបនេះ, «នាងសួរថា «បុគ្គលនោះនៅឯណា?, អើនាង! ចូរនាងទៅសួរព្រះសម្មាសម្ពុទ្ធមើល! » ។ នាងកីសាគោតមីក៏ខំប្រឹងដើរទៅរកព្រះពុទ្ធជាម្ចាស់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំសួរថា «បពិត្រព្រះអង្គដ៏ចម្រើន, ខ្ញុំព្រះអង្គបានឮថា ព្រះអង្គចេះថ្នាំដល់បុត្ររបស់ខ្ញុំព្រះអង្គមែនឬ?» ព្រះអង្គត្រាស់ថា ‹ម្នាលកីសាគោតមី ! តថាគតចេះមែន ថ្នាំសម្រាប់មើលបុត្ររបស់នាង! -បើដូច្នោះ សូមព្រះអង្គប្រោសប្រទានថ្នាំដល់បុត្ររបស់ខ្ញុំព្រះអង្គផង ។ បើនាងចង់ឱ្យកូនរបស់នាងរស់ឡើងវិញ,

ចូរនាងទៅរកគ្រាប់ស្ពៃមួយចិបមកឱ្យតថាគត, -បពិត្រព្រះអង្គដ៏ចំរើន, ឱ្យខ្ញុំព្រះអង្គទៅរកឯណា? -ចូរនាងទៅរកផ្ទះអ្នកណាដែលមិនមានស្លាប់កូននិងចៅមួយសោះនោះ›› ។ នាងក៏ថ្វាយបង្គំព្រះអង្គហើយពកូនដើរចេញទៅក្នុងភូមិមួយ ស្រែកសុំគេថា ‹‹អ្នកទាំងឡាយមានគ្រាប់ស្ពៃដែរឬ? បើមានឱ្យខ្ញុំសុំបន្តិចមក! ››, ជនទាំងឡាយពោលថា ‹‹មាន, ចូរនាងមកយកបន្តិចចុះ! នាងក៏ដើរចូលទៅយកហើយសួរថា ‹‹ផ្ទះរបស់អ្នកទាំងឡាយមានកូនចៅធ្លាប់ស្លាប់ដែរឬ? -មាននាង ។ បើដូច្នោះខ្ញុំមិនយកទេ គ្រាប់ស្ពៃនេះ ។ ជនទាំងឡាយ សួរថា ‹‹ចុះនាង ដើររកគ្រាប់ស្ពៃក្នុងផ្ទះជនដទៃដែលមិនមានមនុស្សស្លាប់ តើព្រោះហេតុអ្វី? -ចាំះអ្នក! ព្រះអង្គឱ្យខ្ញុំរកដើម្បីធ្វើជាថ្នាំដល់បុត្រដែលស្លាប់ហើយនេះឯង ! -អើនាង! មនុស្សទាំង-ឡាយដែលកើតមកហើយ ឈ្មោះថាមិនស្លាប់នោះគ្មានទេ! បើដូច្នោះចូរនាងទៅរកផ្ទះណា ដែលគ្មានមនុស្សស្លាប់នោះចុះ! ›› នាងក៏ខំប្រឹងដើររកយ៉ាងនេះ ចាប់តាំងពីដើមភូមិរហូត

ដល់ចុងភូមិ ក៏នៅតែជនទាំងឡាយពោលដូចៗ គ្នាដដែល ។ នាងក៏ចេញពីចុងភូមិនោះ ហើយដើរដល់ពាក់កណ្ដាលផ្លូវ ក៏គិតថា អញដែលកើតទុក្ខធំដល់ម្ល៉េះ ព្រោះតែបុត្រនេះតើ! នេះចំជាហៅថា មហាទុក្ខ! បើដូច្នេះ មានតែអញបោះកូនដែលស្លាប់នេះចោលទៅ, លុះគិតដូច្នោះហើយ ក៏ក្រវែងកូនស្លាប់នោះចោលទៅក្នុងអរញ្ញប្រទេស ហើយត្រឡប់ចូលមករកព្រះអង្គវិញ ។ ព្រះសាស្ដាមានពុទ្ធដីកាសួរថា នាងបានគ្រាប់ស្ពៃឬទេ ? នាងក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន, ខ្ញុំព្រះអង្គរកមិនបានទេ, ព្រោះថា ជនទាំងឡាយគេតែងពោលថា មនុស្សទាំងឡាយដែលកើតមកហើយ ឈ្មោះថាមិនស្លាប់ទៅវិញនោះគ្មានទេ, ខ្ញុំព្រះអង្គខំប្រឹងដើរសួរយ៉ាងនេះ ចាប់ពីដើមភូមិរហូតដល់ចុងភូមិ ជនទាំងឡាយក៏នៅតែពោលដូចៗ គ្នា ។ ព្រះអង្គត្រាស់ថា ម្នាលនាង! នេះជាធម៌មិនទៀងរបស់សត្វទាំងឡាយ, ដ្បិតថា មច្ចុរាជ តែងកៀរប្រមូលនូវនរណាដែលមានអធ្យាស្រ័យមិនបរិបូណ៌ ឱ្យចូលទៅកាន់

សមុទ្ទគឺអបាយភូមិទាំង ៤ ដូចជាអន្លង់ទឹកជ្រៅ តែងកៀរប្រមូលនូវអ្នកស្រុកដែលកំពុងដេកលក់ហើយទៅ ដូច្នោះឯង; ទើបទ្រង់ត្រាស់សំដែងតទៅទៀតដោយព្រះពុទ្ធដីកាជាគាថាថា:

**តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសន្នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

បច្ចុគឺសេចក្តីស្លាប់ តែងកៀរប្រមូលនូវនរៈដែលមានចិត្តស្រវឹងជ្រប់ក្នុងកូននិងប្រពន្ធ មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ នោះ ដូចជាអន្លង់ទឹកដ៏ជ្រៅ តែងកៀរប្រមូលនូវអ្នកស្រុកដែលកំពុងដេកលក់ហើយទៅដូច្នោះ ។

ក្នុងអវសានគាថា នាងកីសាគោតមី បានសម្រេចសោតាបត្តិផលហើយ សូមបព្វជ្ជាជាភិក្ខុនីភាព ។

សំដែងរឿងនេះ ដើម្បីបញ្ជាក់ឱ្យឃើញច្បាស់ថា អនិច្ចតាសភាពជារបស់មិនទៀង ដូចរឿងដែលពោលមកខាងលើនោះឯង ។

*អនុបាទិន្នកសង្ខារ គឺសង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រង គឺជារបស់ដែលមនុស្សតាក់តែងឡើង ដូចជា កុដិ វិហារ សាលា ជាដើម រមែងធ្លាក់ចុះក្នុងអំណាចនៃលក្ខណៈ ២ យ៉ាង; រួមសេចក្ដីទៅថា សង្ខារអម្បាលនោះ មានលក្ខណៈស្មើគ្នាទាំង ២ គឺ មិនទៀង ជាអនត្តា ដូចគ្នាទាំងអស់ ។*

ចប់តិកៈ ពួក ៣

---

វាយចម្លងចប់ នៅថ្ងៃសៅរ៍ ៨ កើត ខែស្រាពណ៍ ព.ស.២៥៥៦
ត្រូវនឹងថ្ងៃទី ២៥ ខែសីហា គ.ស.២០១២ August 25, 2012

ភិក្ខុបញ្ញាបទីបោ ប៉ាត សុផល
**វត្តរតនរង្សី រីវៀរ**
75 Thornton Street
Revere, MA 02151
Tel: (781) 286-1942
USA